# មាតាបិតុឧបដ្ឋានកថា

ផ្ទះលេខ១៣៦អឹង វិថីទេវភូមិន្ទ រាជធានីភ្នំពេញ

ព.ស.២៥០១

[illegible] elibrary of Cambodia
កក្កដា 2015

# មាតាបិតុឧបដ្ឋានគាថា

INSTITUT BOUDDHIQUE

# មាតាបិតុឧបដ្ឋានកថា

ប្រែចេញពីបាលីក្នុងគម្ពីរមង្គលត្ថទីបនី

អដ្ឋកថាមង្គលសូត្រ

ព្រះឧត្តមមុនី អ៊ុម-ស៊ូរ

អធិបតីរងក្រុមជំនុំព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

គណៈវិន័យមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

បោះពុម្ពលើកទី ៦

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥០១

National Library of Cambodia

00008714

# MÂTÂPITU UPATTHÂNA KATHÂ

TIRÉ DE

ṄGALATTHADĪPANĪ ATTHAKATHĀ MAṄGALASŪTRA

Traduit du Pali par

Préas UTTAMA MUNI Oum-Sou
Vice-Président de la Commission du Tripitaka

Cette Publication a reçu l'approbation
Conseil des Ministres et des deux Chefs de Sectes

Sixième Edition

Phnom-Penh

Editions de l'Institut Bouddhique

1958

មាតាបិតុឧបដ្ឋានកថា នេះ

# ព្រះឧត្តមមុនី អ៊ុម-ស៊ូរ អធិបតីរង

ក្រុមជំនុំព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ

ប្រែនិងរៀបរៀងសេចក្ដី

# ចេញពីបាលីគម្ពីរមង្គលត្ថទីបនី

អដ្ឋកថាមង្គលសូត្រ

## មង្គលសូត្រ ព្រមទាំងអដ្ឋកថា

ក្នុងមង្គលសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ភាសិតសំដែងអំពីមង្គលទាំងឡាយ ៣៨ ប្រការ មានបទថា អសេវនា ច ពាលានំ ដូច្នេះជាដើម ទ្រង់សំដែងដោះអាថ៌ប្រស្នាដែលទេវតាទូលសួរ តែក្នុងទីនេះ មិនបានសំដែងនូវមង្គលទាំងអស់នោះ ឲ្យចប់សព្វគ្រប់ទេ ព្រោះមានឱកាសតិច នឹងសំដែងតែមង្គល ១ ដែលហៅថា មាតាបិតុឧបដ្ឋានមង្គល ជាមង្គលទី ១១ ប្រការ តាមកំឡាំងព្យាយាមអ្នកតែង នឹងអធ្យាស្រ័យអ្នកដែលត្រូវការចង់បាន ។

សំដែងអំពីការទំនុកបំរុងមាតានឹងបិតា ដែលកូនប្រុសស្រីទាំងឡាយ គួរគប្បីធ្វើតបនូវឧបការគុណនោះគ្រប់គ្នា តាមកំឡាំងសទ្ធាចេតនារបស់ខ្លួន ។ ឯការដែលកូនប្រុសស្រីទាំងឡាយ ត្រូវធ្វើឧបត្ថម្ភទំនុកបំរុងមាតានឹងបិតានោះ សម្តេចព្រះសព្វញ្ញុត-ញ្ញាណ ទ្រង់ត្រាស់សរសើរពេកណាស់ថា នរជាតិជន បុរសស្ត្រីឯណា ដែលបានកើតមកក្នុងលោកនេះ ហើយបានធ្វើនូវសេចក្តីគោរពប្រតិបត្តិ លើកតំកើងនូវមាតាបិតារបស់ខ្លួនទាំងនោះ ឲ្យបានតាំងនៅក្នុងគុណធម៌ នឹងគុណសម្បត្តិផ្សេងៗ បុរសស្ត្រីនោះឯង បានឈ្មោះថា ជាអ្នកធ្វើត្រូវលើគឺនរនៃ

សេចក្ដីចំរើនយ៉ាងឧត្ដមបំផុត បានឈ្មោះថា កតញ្ញូ កតវេទីបុគ្គលផង ហើយអ្នកទាំងនោះ គង់នឹងបាន ភប់ប្រសព្វនូវប្រយោជន៍ នឹងសេចក្ដីសុខគ្រប់យ៉ាង ក្នុងលោកនេះ នឹងលោកខាងមុខពុំខានឡើយ ។

ឯពាក្យដែលហៅថា មាតាបិតានេះ ប្រសិនបើ មានគេសួរថា ដែលហៅម្ដាយអាពុកថា "មាតាបិតា" នោះ តើជាភាសាអ្វី ស្ដ្រីដូចម្ដេច ដែលហៅថា មាតា បុរសយ៉ាងណា ដែលហៅថា បិតា ។

ត្រូវឆ្លើយថា ពាក្យដែលហៅថា "មាតាបិតា" នោះ ជាភាសាបាលីសុទ្ធ ។

មាតា នាម ជនិកា បិតា នាម
ជនកោ តេសុ មាតរិ ទុក្ករការិកា
ស្ដ្រីឯណា ដែលជាអ្នកអាចដើម្បីញុំាងកូន

កើតឡើងបាន ស្ត្រីនោះ បាននាមបញ្ញត្តិថា មាតា គឺម្ដាយ ប្រុសឯណា ដែលជាអ្នកអាចញ៉ាំងកូនឲ្យកើតឡើងបាន ប្រុសនោះ បាននាមបញ្ញត្តិថា បិតា គឺអាពុក ។ ជំនុំអ្នកទាំងពីរ គឺមាតានឹងបិតានោះ បំណែកខាងមាតាតែម្យ៉ាង ក៏ជាអ្នកធ្វើនូវឧបការកិច្ចដល់កូនយ៉ាងធ្ងន់ក្រៃពេក កម្រអ្នកណាមួយនឹងធ្វើត្រាប់បានឡើយ ឯកូនប្រុសស្រីសោត ក៏កម្រនឹងធ្វើស្នង ឬ ធ្វើជំនួសវិញបាន ព្រោះមាតានោះជាអ្នកមានឧបការគុណដល់កូនទាំងឡាយ ដោយច្រើនជាបំផុត ហេតុនេះហើយ បានជាព្រះបរមសាស្តាសម្មាសម្ពុទ្ធជាគ្រូ កាលដែលព្រះអង្គទ្រង់យោនយកកំណើត កើតជាព្រះតាបសឫសីម្នាក់ ទ្រង់ព្រះនាមថា សោណបណ្ឌិតបរមពោធិសត្វ

ព្រះអង្គទ្រង់ប្រកាសនូវទុក្ករការកកិច្ចរបស់មាតានោះ ជាពាក្យរំលឹកទូន្មាន ដល់មហាក្សត្រទាំងឡាយ ច្រើនព្រះអង្គ ក្នុងសុកលជម្ពូទីបនេះ សឹងមាន ជាបទគាថា សំដែងទុកនៅក្នុងសោណនន្ទជាតក ក្នុងសត្តតិនិបាត ថាដូច្នេះ :

អាកង្ខមានា បុត្តផលំ ទេវតាយ នមស្សតិ
នក្ខត្តានិ ច បុច្ឆតិ ឧតុសំវច្ឆរានិ ច ។ តស្សា
ឧតុសិ នហាតាយ ហោតិ គព្ភស្សាវក្កមោ តេន
ទោហឡិនី ហោតិ សុហទា តេន វុច្ចតិ ។
សំវច្ឆរំ វា ឩនំ វា បរិហរិត្វា វិជាយតិ តេន សា
ជនយន្តី ច ជនេត្តី តេន វុច្ចតិ ។ ថនក្ខីរេន
គីតេន អង្គបាវុរណេន ច រោទន្តំ បុត្តំ
តោសេតិ តោសេន្តី តេន វុច្ចតិ ។ តតោ

អាគាតបេ ឃោរេ មម្មំ កត្វា ឧទិក្ខតិ ទារកំ
អប្បិយានំ បាហេសំ តេន វុច្ចតិ ។ យញ្ច
មាតុធនំ ហោតិ យញ្ច ហោតិ បិតុទ្ធនំ ឧភយម្បេ
តស្ស គោបេតិ អបិ បុត្តស្ស នោ សិយា ។
ឯវំ បុត្ត អទុំ បុត្ត ឥតិ មាតា វិហញ្ញតិ
បមត្តំ បរទារេសុ និសីថេ បត្តយោព្វនេ
សាយំ បុត្តំ អនាយន្តំ ឥតិ មាតា· វិហញ្ញតិ ។

សេចក្តីក្នុងគាថានេះថា អ្នកជាមាតា លោកតែងធ្វើនូវសេចក្តីនមស្សការ បែរបន់ប៉ួងសួងដល់ទេវតាទាំងពួងថា សូមទេវតាជាម្ចាស់ទាំងអស់ជួយខ្ញុំ ៗ សូមឲ្យបានកូនប្រុស ឬកូនស្រី ចូលមកចាប់យកបដិសន្ធិក្នុងផ្ទៃនៃខ្ញុំកុំខាន ហើយអ្នកមាតានោះតែងសួរនូវនក្ខត្តឫក្សទាំងឡាយ ដល់អ្នកចាស់ព្រឹទ្ធាចារ្យ

ទាំងពួងថា លោកតា លោកយាយ កូនគេមុន ៗ ដែលមានអាយុវែងនោះ តើគេកើតមកត្រូវលើថ្ងៃណា ខែណា ដែលមានអាយុខ្លីនោះ តើគេកើតមកក្នុងថ្ងៃដូចម្ដេច ខែដូចម្ដេច ហើយអ្នកតែងសួរនូវរដូវនឹងឆ្នាំទាំងឡាយទៀតថា កូនអ្នកទាំងពួងមុនៗ ដែលគេមានអាយុយឺននោះ តើគេធ្លាប់កើតក្នុងរដូវអ្វី ឆ្នាំអ្វី ដែលមានអាយុខ្លីនោះ តើគេតែងកើតក្នុងរដូវដូចម្ដេច ឆ្នាំដូចម្ដេច ។

ម្យ៉ាងទៀត កាលបើផ្កា គឺឈាមរដូវសម្រាប់ស្ត្រី កើតឡើងបរិបូណ៌ហើយ ៗ រាំងរដូវ ឬ រាំងខែនោះបាត់ទៅ សត្វដែលបំរុងនឹងកើត ក៏បែរមុខបំពោះឈានចូលមកចាប់បដិសន្ធិ ក្នុងផ្ទៃនៃមាតានោះតាមសេចក្ដីប្រាថ្នា ។

មួយទៀត មានន័យក្នុងមហាតណ្ហាសំខយសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក មហាយមកវគ្គ ប្រាប់សេចក្ដីថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងនូវដំណើរនៃសត្វទាំងឡាយ ដែលកើតក្នុងផ្ទៃនៃមាតាក្នុងលោកនេះ ប្រាប់ដល់ភិក្ខុទាំងឡាយជាសាវកថា :

ឥធ តិណ្ណំ ខោ បន ភិក្ខវេ សន្និបាតា(១)
គព្ភស្ស(២) វក្កន្តិ ហោតិ ។

សេចក្ដីថា នែភិក្ខុទាំងឡាយ ឯសត្វទាំងពួង ដែលនឹងឈានចូលមកចាប់យកបដិសន្ធិក្នុងផ្ទៃនៃមាតានោះ លុះតែមានកិច្ចជាទីប្រជុំ ប្រកបដោយអង្គ ៣ ប្រការនោះ មកជួបជុំព្រមផង ទើបអាច

១ អដ្ឋកថាមង្គលសូត្រថា សន្និបាតានំ ។ ២ គព្ភស្សវក្កន្តិ ។

កើតបាន បើខ្វះអង្គឯណា ១ ក៏មិនអាចកើតបាន ឯអង្គ ៣ ប្រការនោះគឺ :

១- មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតាបិតាបានធ្វើសេវនកិច្ចជាមួយគ្នា ដោយសេចក្ដីតម្រេកតែម្យ៉ាងផង ។

២- មាតា ច ឧតុនី ហោតិ ចំណែកខាងមាតា ក៏មានឧតុសម័យដ៏ស្រួលបួលគឺ មានទីកន្លែងសម្រាប់សត្វដែលកើតក្នុងផ្ទៃនោះ ក៏ជាទីស្អាតបរិសុទ្ធល្អល្មមសត្វនឹងចូលទៅកើតបានផង ព្រោះឈាមសំរាប់រដូវនោះ ក៏បែកហូរហៀរចេញអស់ហើយ ។

៣- គន្ធព្វោ ច បច្ចុបដ្ឋិតោ ហោតិ សត្វដែលបំរុងនឹងចូលទៅកើតក្នុងទីនោះ ក៏មានប្រាកដផង ។

ឯកំណើតសត្វ ដែលនឹងកើតក្នុងផ្ទៃនៃមាតា

បានគោះ លុះតែប្រកបដោយអង្គ ៣ ប្រការនេះ បើខ្វះអង្គឯណា ១ ហើយ មិនអាចនឹងកើតបាន ឡើយ ដូចមានពុទ្ធភាសិត ក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក ទ្រង់សំដែងទុកមកថា :

ឥធ មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតា ច ន ឧតុនី ហោតិ គន្ធព្វោ ច ន បច្ចុបដ្ឋិតោ ហោតិ នេវ តាវ គព្ភស្សាវក្កន្តិ ហោតិ ។ ឥធ មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតា ច ឧតុនី ហោតិ គន្ធព្វោ ច ន បច្ចុបដ្ឋិតោ ហោតិ នេវ តាវ គព្ភស្សាវក្កន្តិ ហោតិ ។ យតោ ច ខោ ភិក្ខវេ មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតា ច ឧតុនី ហោតិ

គន្ធព្វោ (១) ច បច្ចុបដ្ឋិតោ ហោតិ ។ ឯវំ តិណ្ណំ សន្និបាតា គព្ភស្សាវក្កន្តិ ហោតិ ។

សេចក្ដីថា មាតាបិតា បានរួមធ្វើសេវនកិច្ចជាមួយគ្នាហើយ តែបំណែកខាងមាតា មិនមានឧតុសម័យដ៏ស្រួលបួល ទាំងសត្វដែលបំរុងនឹងចូលមកកើតនោះទៀត ក៏មិនមានផង យ៉ាងនេះ សត្វក៏នឹងមិនអាចកើតបាន ។

មាតាបិតា បានរួមធ្វើសេវនកិច្ចជាមួយគ្នា ទាំងមាតាក៏មានឧតុសម័យដ៏ស្រួលបួល តែបំណែកខាងសត្វដែលបំរុងនឹងកើតពុំមាន សត្វក៏នឹងមិនអាចកើតបាន ។

លុះតែមាតាបិតា បានធ្វើសន្និបាតកិច្ចជាមួយគ្នា

---

១ គន្ធព្វោតិ គត្រូបគសត្តោ ។

១ ចំណែកខាងមាតា ក៏មានឧតុសម័យដ៏ស្រួល បួល ១ សត្វដែលបំរុងនឹងកើតក៏មានមកប្រាកដ ១ បានប្រកបដោយអង្គ ៣ ប្រការនេះហើយ ទើបសំរេចកំណើតសត្វបាន ។

ម្យ៉ាងទៀត ចំណែកខាងមាតា តាំងពីខ្លួនមានគភ៌ប្រាកដឡើងវេលាណាហើយ ក៏បានឈ្មោះថាទោហឡិនី(១) ជាស្រីចាញ់ផ្ទៃហើយ ឬ ជាស្រីមានសេចក្ដីចំណង់ផ្សេង ៗ តែងមានសេចក្ដីស្នេហាកើតឡើងចំពោះទៅត្រង់សត្វ ដែលអាស្រ័យនៅក្នុងផ្ទៃនោះជានិច្ច ព្រោះហេតុនេះហើយ បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ហៅមាតានោះថាសុហទា ជាស្រីមានសន្ដានចិត្តល្អ ហួរទៅកាន់

---

១ ទោហឡិនី ដែលធ្លាប់ប្រែមកថា ស្រីមានសេចក្ដីប្រាថ្នាពីរ ។

កូន ជនយិត្តី ៈ ជាស្ត្រីអ្នកញុំាងកូនឲ្យកើតបាន ជនេត្តី ៈ ជាស្ត្រីអ្នកបង្កើតនូវកូនបាន ។

ម្យ៉ាងទៀត មាតានេះ មិនមែនគ្រាន់តែមានចិត្តល្អនឹងអាចបង្កើតកូនបានប៉ុណ្ណោះទេ គឺជាអ្នកអាចបេះបែរក្សាកូនទាំងនោះ ឲ្យបានស្ថិតនៅជាសុខក្នុងផ្ទៃជរាបដល់អស់[1] ១ ឆ្នាំ ឬ ថយពី ១ ឆ្នាំ រហូតដល់បានសម្រាលចេញមក លុះដល់កូននោះកើតមកហើយៗ បើកូនតូចៗ ទាំងនោះ ស្រែកយំឡើងវេលាណា អ្នកមាតាក៏តែងនឹងយកកូនតូចនោះមកដាក់ផ្តេកផ្តិតនៅជិតបន្លោះនៃដោះទាំងពីរ ដើម្បីនឹងផ្សព្វផ្សាយនូវសម្ផស្សកាយ បំបាយធាតុរបស់ខ្លួនឲ្យជ្រាបចូលទៅកាន់សាច់ឈាមនៃកូននោះបាន

---

១ ក្នុងគម្ពីរមជ្ឈិមនិកាយថា កូនដែលនៅក្នុងផ្ទៃមាតាប្រមាណ ៩ ខែ ឬ ១០ ខែ ក្នុងអដ្ឋកថាមង្គលសូត្រថា ១ ឆ្នាំ ឬ ថយចុះពី ១ ឆ្នាំមក ។

ហើយអ្នកមាតា បេះល្បួងលោមនូវកូនតូច ៗ នោះ ឲ្យត្រេកអរដោយរសនៃទឹកក្បួររបស់ខ្លួន នឹង សំឡេងបំពេ សំឡេងចម្រៀងនោះផង ព្រោះហេតុនឹងហើយ បានជាសម្ដេចព្រះភគវា ទ្រង់ត្រាស់ហៅមាតានោះថា គោសេដ្ឋី ជាស្ត្រីបេះល្បួងលោម ប្រឡែងនឹងកូន ដែលមិនទាន់ដឹងក្ដី ឲ្យត្រេកអរបាន។

ម្យ៉ាងទៀត មាតានោះ អ្នកតែងក្រឡេកមើល ទៅកាន់កូនតូច ដោយហឫទ័យយ៉ាងស្និទ្ធ ព្រោះបិត្តស្រឡាញ់ ហើយអ្នកតែងគិតថា នុកូនតូចអញអើយ ប្រហែលជាខ្យល់ប្រហារបោកបក់ត្រូវខ្លាំងដឹង ឬ មានកំដៅក្ដៅ ផ្សាយបំពាយត្រូវខ្លាំង ដល់កូនតូច ដែលជាអ្នកមិនទាន់ដឹងក្ដីនោះដឹង អ្នកមាតាតែងគិតរំពឹងយ៉ាងនេះ ។

ន័យ ១ ទៀត មានពុទ្ធភាសិត ទ្រង់ត្រាស់សរសើរគុណមាតានោះ ជាអនេកបរិយាយ ក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក ប្រាប់ភិក្ខុទាំងឡាយថា នែភិក្ខុទាំងឡាយ មាតាមានសន្តានចិត្តយ៉ាងល្អប្រព្រឹត្តទៅក្នុងកូនក្រៃពេកណាស់ គឺជាអ្នកតាំងចិត្តថែរក្សាឆ្វរកូន ដែលអាស្រ័យនៅក្នុងផ្ទៃរបស់ខ្លួននោះ មិនមែនឆាប់ទេ គឺអ្នកមាតាប្រឹងទ្រទ្រង់ឆ្វរគភ៌ដ៏ធ្ងន់នោះ ប្រមាណដល់ ១០ ខែ ឬ ៩ ខែ ព្រម-ទាំងសេចក្តីសន្ទិះសង្ស័យ អាល័យក្នុងជីវិតរបស់ខ្លួនក្រែងពុំទៀងផង នែភិក្ខុទាំងឡាយ ឯមាតានេះអ្នកតែងតាំងចិត្តគិតយ៉ាងសុខុម ព្រមទាំងសេចក្តីព្យាយាមយ៉ាងខ្លាំង ក្នុងកិច្ចដែលនឹងថែរក្សាចិញ្ចឹមឆ្វរកូននោះ ជាទីបំផុតពេកណាស់ នឹងរកកិច្ច

ឯណា ១ ក្នុងលោកនេះ ឲ្យជាធំវិសេស ជាងកិច្ច ដែលមាតាបិតារក្សាកូននោះគ្មានទេ គឺអ្នកបានបង្ហូរ បង្ហូតឈាមរបស់ខ្លួន ឲ្យហូរហៀរបេញពីដើមទ្រូង របស់អ្នកស្រស់ ៗ ចូលក្នុងមាត់កូនកំពុងយំ ឬកំពុង ឃ្លាន ឲ្យបាត់វេទនានោះមួយរំពេចបាន ។ ឯឈាម ដែលបង្ហូរបេញពីដើមទ្រូង តាមសណ្ដាប់ដោះ ទាំងពីរនោះ មានពណ៌ស ដែលលោកហៅថា ទឹកដោះ ៗ នោះ បានជាមានពណ៌ស ព្រោះ បិត្តមាតាដែលនឹងបិញ្ចឹមរក្សាកូនឲ្យបៅដោះនោះ ដោយសេចក្ដីករុណាជាការុញ្ញភាព ហើយអ្នក មាតាដែលបិញ្ចឹមរក្សាកូននោះទៀត មិនមែនតាំង បិត្តមានកំណត់ត្រឹមបែរក្សាគភ៌នឹងបំបៅដោះ ដូច មេសត្វទាំងពួងនោះទេ គឺអ្នកតាំងបិត្តរក្សាជំរាប

ដល់ផុតជីវិតនៃខ្លួន ព្រោះហេតុនេះហើយ បានជាសម្តេចព្រះពិជិតមារ ទ្រង់ត្រាស់ហៅមាតានោះថា បោសេត្ថី ជាស្រីអ្នកបេះបិញ្ចមកូនតូចៗ ពុំទាន់ដឹងក្តីខុសត្រូវនៅឡើយ ឲ្យបំរើនឡើងបាន ។

ម្យ៉ាងទៀត ទ្រព្យសម្បត្តិទាំងពីរបំណែក គឺបំណែកខាងខ្លួននឹងខាងស្វាមី អ្នកមាតាខំរក្សាទុកដាក់យ៉ាងល្អក្នុងស្លែង សម្រាប់ដាក់ទ្រព្យសម្បត្តិដែលមានខ្លឹមសារទាំងពួង ហើយអ្នកមិនដែលបញ្ចេញវាចាប្រាប់អ្នកណាឲ្យដឹងផងឡើយ ព្រោះអ្នកតាំងចិត្តបំរុងថា ទ្រព្យសម្បត្តិទាំងនោះ ទុកឲ្យកូនទាំងឡាយនោះឯង លុះដល់កូននោះដឹងសេចក្តីគ្រប់សព្វហើយ មាតាតែងប្រដៅរំលឹកដាស់តឿនកូនទាំងនោះថា នែកូន អ្នកកុំមានចិត្តធ្វេសប្រហែស

ឡើយ កុំប្រមាថក្នុងត្រកូលទាំងឡាយ មានត្រកូលស្ដេចជាដើម ហើយកូនត្រូវខំសង្វាតរករៀនបំណោះវិជ្ជា ព្រមទាំងភាសាផ្សេងៗផង ត្រូវខំព្យាយាមរៀនធ្វើការងារយ៉ាងនេះ យ៉ាងនោះផង លុះដល់កូនទាំងនោះ មានវ័យវឌ្ឍនាការ បំរើនធំពេញកំឡោះក្រមុំហើយ អ្នកមាតាក៏បាននូវសេចក្ដីទុក្ខព្រួយពីរ–បីយ៉ាងទៀតមកបន្ថែម គឺមាតាតែងគិតដល់កូនប្រុសៗនោះថា នូកូនអញទាំងនេះ មិនដឹងជាយ៉ាងណា ក្រែងលោទៅប្រព្រឹត្តធ្វើអំពើអនាចារ នឹងស្រីជាប្រពន្ធអ្នកដទៃ ឲ្យគេកើតសេចក្ដីក្ដៅក្រហាយ គេនឹងធ្វើឲ្យវិនាសដោយហេតុឯណា ១ ដឹង ។ ម្យ៉ាងទៀត តែដល់វេលាល្ងាចជិតព្រលប់ ហើយបាត់កូនមិនឃើញមកដល់ផ្ទះ អ្នកតែងមានចិត្ត

ព្រួយបារម្ភយ៉ាងខ្លាំង ជួនកាលមានទឹកភ្នែករលេង រលោងដោរផលឡើងក៏មាន ហើយខំរំពឹងរំពៃ មើលផ្លូវ ខំស្តាប់សព្ទសំឡេងកូនរាល់ពេល ព្រោះហេតុនេះហើយ បានជាលោកម្តាយ លោកអាពុកនោះ មានគុណនឹងកូនប្រុសស្រីទាំងនោះ រឹតរឹងតែបំរើនឡើង ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សំដែងកំណត់នូវគុណនាម របស់អ្នកមានគុណទាំងពីរនោះ ជា ៤ យ៉ាង ដូចមានបទបាលីថា :

ឧភោបិ បេតេ ព្រហ្មា បុព្វទេវា
បុព្វាចរិយា អាហុនេយ្យាតិ ច បវុច្ចន្តិ ។

សេចក្តីថា អ្នកដ៏មានគុណទាំងពីរនាក់នោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់សំដែងឲ្យឈ្មោះជា ៤ ឋានគឺ ឋានទី ១ ហៅថា ព្រហ្មា

ឋានទី ២ ហៅថា បុព្វទេវា ឋានទី ៣ ហៅថា បុព្វាចារិយា ឋានទី ៤ ហៅថា អាហុនេយ្យា តាមកំឡាំងឧបការគុណរបស់អ្នកទាំងពីរនោះ ។

ត្រង់នាមទី ១ ដែលហៅមាតាបិតាថា ព្រហ្មា ។ នោះប្រែថា អ្នកដ៏ប្រសើរ មានសេចក្តីអធិប្បាយថា មាតាបិតា ដែលអាចនឹងចិញ្ចឹមរក្សាកូនទាំងឡាយបាន ក៏ព្រោះតែអ្នកទាំងពីរនោះ មានចិត្តប្រកបដោយភាវនា ៤ យ៉ាងគឺ មេត្តាភាវនា ករុណាភាវនា មុទិតាភាវនា ឧបេក្ខាភាវនា ប្រព្រឹត្តចំពោះទៅត្រង់កូនប្រុស-ស្រីទាំងឡាយជានិច្ចឥតមានអាក់ មិនដែលលះបង់គំនិតទាំង ៤ ប្រការនេះចេញឲ្យឆ្ងាយអំពីកូនខ្លួនឡើយ ប្រៀបដូចមហាព្រហ្មទាំងឡាយដែលរក្សាឈានរបស់ខ្លួនទុកមិនឲ្យវិនាស - ធម្មតា

មហាព្រហ្មទាំងឡាយ ដែលនឹងរក្សាឈានទុកបាន នោះ ក៏ព្រោះមហាព្រហ្មទាំងនោះ មានចិត្តប្រកប ដោយព្រហ្មវិហារ ៤ ប្រការគឺ មេត្តាព្រហ្មវិហារ ករុណាព្រហ្មវិហារ មុទិតាព្រហ្មវិហារ ឧបេក្ខាព្រហ្មវិហារ មហាព្រហ្មទាំងឡាយ មានព្រហ្មវិហារ យ៉ាងនេះឯង ទើបរក្សាឈាននោះទុកនៅបាន ហេតុដូច្នេះហើយ បានជាព្រះបរមសាស្តា សម្មាសម្ពុទ្ធទ្រង់បញ្ញត្តនាមរបស់អ្នកមានគុណទាំង ពីរនោះ ហៅថា ព្រហ្ម ឬថា មហាព្រហ្ម ។

សួរថា មាតាបិតា ដែលមានមេត្តាចិត្តកើត ឡើងដល់កូននោះ តើតាំងពីត្រឹមថ្ងៃណា ខែណា មក នឹងមានគំនិតគិតដូចម្តេចទៅដល់កូន ។

ឆ្លើយថា មាតាបិតា ដែលមានមេត្តាចិត្តកើត

ឡើងដល់កូន តាំងពីថ្ងៃ ខែដែលអ្នកមាតាដឹង ប្រាកដក្នុងខ្លួនថា ខ្លួនអញមានសត្វគឺកូន មកអាស្រ័យនៅក្នុងផ្ទៃហើយៗ អ្នកទាំងពីរ តែងមានគំនិតគិតថា កាលណា វេលាណា យើងនឹងបានឃើញនូវកូនតូចរបស់យើង ជាកូនមានរោគ ឬ ឥតរោគដូចម្ដេចហ្ន៎ ។

គំនិតយ៉ាងនេះឯង ទើបបានឈ្មោះថា មេត្តាចិត្ត ឬ មេត្តាព្រហ្មវិហារ កើតឡើងដល់មាតា ក្នុងកាលនោះឯង មេត្តាចិត្ត ប្រែថា មាតាបិតា មានចិត្តដ៏ល្អទៅកាន់កូន ឬថា មានចិត្តរាប់អានស្រឡាញ់កូន មេត្តាព្រហ្មវិហារ ប្រែថា មាតាបិតា មានទីលំនៅដ៏ប្រសើរ គឺមេត្តា ឬថា មានធម៌សម្រាប់នៅនៃព្រហ្ម គឺមេត្តា ។

បុះមាតាបិតា ដែលមានករុណាចិត្ត កើតឡើងដល់កូននោះ តើពីត្រឹមកាលណាមក ។

មាតាបិតា ដែលមានករុណាចិត្ត កើតឡើងដល់កូននោះ ក្នុងពេលដែលកូននោះ បានសម្រាលបេញផុតអំពីទ្វារមាសនៃមាតាមកក្រៅហើយ ។ ស្រែកយំយ៉ាងខ្លាំង ដោយសេចក្តីទុក្ខព្រួយឯណាមួយ ដែលមកប៉ះពាល់ត្រូវកាយ លុះអ្នកទាំងពីរបានឮសំឡេងយំនោះហើយ អ្នកក៏មានចិត្តអាណិតអាសូរ ករុណាយ៉ាងខ្លាំង ទៅដល់កូននោះ ទើបបានឈ្មោះថា ករុណាចិត្ត ឬ ករុណាព្រហ្មវិហារ កើតឡើងក្នុងវេលានោះ ។ ករុណាចិត្តប្រែថា មាតាបិតា មានចិត្តប្រកបដោយសេចក្តីអាណិតអាសូរទៅកាន់កូន ។

បុះមាតាបិតា ដែលមានមុទិតាបិត្ត កើតឡើង ដល់កូននោះ ក្នុងវេលាណា ។

ជាអ្នកទាំងពីរ ដែលមានមុទិតាបិត្តកើតឡើង ដល់កូននោះ ក្នុងពេលដែលកូននោះ បេះដើរ បេះ លេង នឹងក្នុងកាលដែលកូននោះ បានបំរើនដោយ គុណដ៏ល្អ ទើបមាតាបិតា មានបិត្តរីករាយស្រស់ ស្រាយទៅដល់កូននោះ ក៏បានឈ្មោះថា មុទិតា បិត្ត ឬ មុទិតាព្រហ្មវិហារ ក្នុងវេលានោះ មុទិតា បិត្ត ប្រែថា មាតាបិតា មានបិត្តប្រកបដោយ សេចក្ដីរីករាយទៅកាន់កូន ។

បុះមាតាបិតា ដែលមានឧបេក្ខាបិត្ត កើតឡើង ដល់កូននោះ តើក្នុងពេលណា ។

ជាអ្នកមានគុណទាំងពីរ ដែលមានឧបេក្ខាបិត្ត

កើតឡើងដល់កូននោះ ក្នុងកាលដែលកូននោះបាន បំរើនឡើង មានផ្ទះសំបែង មានប្ដីប្រពន្ធ បេះរកស៊ី ធ្វើការចិញ្ចឹមជីវិត តាមទំនើងខ្លួនឯងបាន អ្នកម្ដាយ អ្នកអាពុកមានចិត្តជាកណ្ដាល មិនសូវព្រួយពេក ព្រោះកូនអាចរក្សាខ្លួនឯងបានហើយ ទើបបាន ឈ្មោះថា ឧបេក្ខាចិត្ត ឬ ឧបេក្ខាព្រហ្មវិហារ ក្នុងពេលនោះ ។

ឧបេក្ខាចិត្ត ប្រែថា មាតាបិតា មានចិត្តតាំងនៅ ក្នុងអារម្មណ៍ជាកណ្ដាលទៅរកកូន ឯមាតានឹងបិតា ទាំងពីរនេះ តែងតាំងនៅក្នុងធម៌ ៤ ប្រការ មិន ដែលដាច់ជាធម្មតា ហេតុយ៉ាងនឹងហើយ បានជា ព្រះសយម្ភូញាណ ទ្រង់ត្រាស់កំណត់នូវនាមនៃអ្នក ដ៏មានគុណទាំងពីរនោះ ឲ្យឈ្មោះថា ព្រហ្មៗដូច្នេះ

ឯវន្តេសំ បុត្តេសុ យថាកាលំ ចតុព្វិធស្សាបិ ព្រហ្មវិហារស្ស លភន្តោ ព្រហ្មសទិសវុត្តិតាយ ព្រោះសេចក្តីថា អ្នកដ៏មានគុណទាំងពីរនោះ មានកិរិយាប្រព្រឹត្តិនូវធម៌ប្រហែលគ្នានឹងមហាព្រហ្ម គឺអ្នកទាំងនោះ តែងបាននូវព្រហ្មវិហារ ៤ ប្រការ ប្ញូរទៅកាន់កូនទាំងឡាយ ដោយប្រការ ដូចជាពោលមកហើយនោះ ។

ឆាមទី ២ ដែលហៅថា បុព្វទេវា ៗ នោះ ប្រែថា ទេវតាមានហើយក្នុងកាលមុន មានសេចក្តីអធិប្បាយថា មាតាបិតាទាំងពីរនេះ ដែលអាចនឹងទំនុកបំរុង ស្វែងរកប្រយោជន៍ឲ្យកូនបាននោះ បានតាំងចិត្តមិនប្រកាន់ទោសខុស គឺមិនអើពើនឹងសេចក្តីឆ្គាំឆ្គង ដែលកូនទាំងឡាយធ្វើឲ្យភ្លាំងភ្លាត់

ហើយដល់អ្នកទាំងនោះ មានតែគំនិតមួយ ខំ ខ្នះខ្នែងស្វែងរកសេចក្តីចំរើន និងសេចក្តីសុខដល់ កូន អ្នកមាតាបិតានេះ មានសភាពហាក់ដូចជា ទក្ខិណេយ្យបុគ្គលដ៏ប្រសើរ តែងនាំមកនូវផលា និសង្សយ៉ាងច្រើន រាប់ដោយរយចំពូកមកឲ្យកូន ទាំងឡាយ ដែលកូនទាំងឡាយបានធ្វើតបឧបការ គុណដល់ខ្លួនអ្នកជាមាតាបិតានោះ មាតាបិតា នេះ លោកតែងប្រៀបថា ដូចវិសុទ្ធិទេវា គឺព្រះ ខីណាស្រព ធម្មតាព្រះខីណាស្រព លោកមិន ដែលមានចិត្តប៉ឹងប៉ោក់អាក់អន់ ទៅរកមនុស្សពាល មនុស្សល្ងង់ ដែលធ្វើទោសដល់លោកឡើយ មានតែព្រះហឫទ័យម្យ៉ាង ប្រាថ្នារកគុណ និង ប្រយោជន៍ ឲ្យកើតឡើងដល់មនុស្សពាលល្ងង់នោះ

ហើយជនពាលទាំងនោះ បានធ្វើនូវសេចក្ដីគោរព រាប់អានដល់លោក ក៏អាចនឹងបាននូវគុណ និង ប្រយោជន៍ច្រើន រាប់ដោយរយបំពួកជាប្រមាណ ព្រោះតួអង្គវិសុទ្ធទេវា នោះ លោកជាទក្ខិណេយ្យ បុគ្គលដ៏ប្រសើរ ព្រោះហេតុប៉ុណ្ណោះហើយ បាន ជាសម្ដេចព្រះអនន្តញាណ ទ្រង់ប្រោសប្រទាននាម បញ្ញត្តិរបស់មាតាបិតានេះថា ទេវា ៗ ជួប្លេះ ទេវ សទិសវុត្តិតាយ ព្រោះសេចក្ដីថា មាតាបិតាទាំង ពីរនាក់នោះ លោកតែងប្រព្រឹត្តស្វែងរកប្រយោជន៍ ឲ្យកូនទាំងឡាយ ដូចជាវិសុទ្ធទេវានោះឯង ។

ម្យ៉ាងទៀត កូនប្រុសស្រីទាំងឡាយ ដែលបាន ដឹងស្គាល់នូវទេវតាទាំងឡាយ៣ពួកគឺ សម្មតិទេវា ទេវតាដែលអ្នកស្រុកគេសន្មតឲ្យជាធំ ជាម្ចាស់លើ

ផែនដី គឺស្ដេច ១ ឧបបត្តិទេវា ទេវតាដែលកើត
ឯង ដោយកំឡាំងផល ១ វិសុទ្ធិទេវា ទេវតាដែល
មានសន្ដានចិត្តស្អាតបរិសុទ្ធិ ផុតសេចក្ដីសៅហ្មង
ទាំងពួង គឺព្រះខីណាស្រព មានព្រះពុទ្ធជាដើម ១
ហើយកូនទាំងនោះ អាចធ្វើនូវសេចក្ដីគោរព ដល់
ស្ដេចជាម្ចាស់ផែនដីផង ដឹងនូវធម៌របស់ទេវតាទាំង
៤ យ៉ាង មានសទ្ធាជាដើម ដែលជាធម៌តែងធ្វើ
មនុស្សដែលបានប្រតិបត្តិតាម ឲ្យទៅកើតជាឧបបាតិក
ទេវតាផង និងបេះគោរពរាប់អាន នូវព្រះខីណា-
ស្រពទាំងឡាយ មានព្រះពុទ្ធជាដើម ឲ្យបានត្រាស់
ដឹងនូវមគ្គនឹងផលផង ។ ឯកូនប្រុសស្រីទាំងឡាយ
ដែលបានស្គាល់នូវទេវតាទាំង ៣ ពួកនេះក្ដី បាន
បេះគោរពប្រតិបត្តិនូវទេវតាទាំងនោះក្ដី ក៏មិនមែន

បានដឹងមកអំពីអ្នកឯណាឡើយ គឺបានដឹងមកអំពីមាតាបិតាលោកបានបង្កើត បានប្រាប់ពន្យល់ជាមុនទើបបានដឹង ហេតុដូច្នេះ ទើបបានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តនាមរបស់មាតាបិតាទាំងនោះថា បុព្វទេវា ៗ ប្រែថា ទេវតាមានហើយក្នុងកាលមុន ឬ ទេវតាមុនជាងទេវតាទាំងពួងក៏បាន ឯទេវតាទាំង ៣ ពួក មានសម្មតិទេវា ជាដើមនោះ ព្រះសព្វញ្ញុតញ្ញាណ ទ្រង់កំណត់ឈ្មោះថា បច្ឆាទេវា ប្រែថា ទេវតាមានហើយក្នុងកាលជាខាងក្រោយ ឬថា ទេវតាជាន់ក្រោយក៏បាន ។

នាមទី៣ដែលហៅថា បុព្វាចរិយៗនោះ ប្រែថា អាចារ្យមានហើយក្នុងកាលមុន ឬថា អាចារ្យមុនដំបូង មានសេចក្ដីអធិប្បាយថា មាតាបិតា ជាអ្នក

បង្ហាត់បង្ហាញ បង្រៀននូវកូនប្រុសស្រីទាំងឡាយ ច្រើនបែប ច្រើនយ៉ាងពេក មានបង្រៀនឲ្យចេះផឹក ចេះស៊ី ចេះអង្គុយ ចេះឈរ ចេះដើរ ជាដើមផង បង្រៀនឲ្យចេះហៅជីដូន ជីតា មា មីង ជាដើមផង ចាប់ដើមតាំងអំពីថ្ងៃដែលកូននោះកើតហើយ អ្នកក៏ចេះតែមានកិច្ចការ បង្ហាត់បង្រៀនកូននោះរាល់ពេល ដរាបដល់កូននោះ ចេះប្រើឥរិយាបថសមគួរគ្រប់យ៉ាង និងចេះនិយាយសំដីគួរសមទៅរកអ្នកធំ អ្នកតូចទាំងពួងបាន ព្រោះហេតុនេះហើយ បានជាព្រះអនាវរណញ្ញាណ ទ្រង់ប្រោសប្រទានឈ្មោះមាតាបិតានោះ ហៅថា បុព្វាចារិយៈ ថាជាអាចារ្យមុនអាចារ្យទាំងពួង ។ ឯលោកអាចារ្យទាំងពួង ក្រៅអំពីមាតាបិតានេះ ហៅថា បច្ឆាចារិយៈ ប្រែថា អាចារ្យមាន

ហើយក្នុងកាលជាខាងក្រោយ ឬថា អាចារ្យជាន់ក្រោយ ព្រោះលោកគ្រូអាចារ្យទាំងនោះ លោកខ្លះបានបង្រៀនសិល្បសាស្ត្រ ខ្លះបានប្រាប់ត្រៃសរណគមន៍ ប្រាប់សីលទាំងឡាយ ខ្លះជាអ្នកបំបួស ខ្លះជាអ្នកបង្រៀនព្រះត្រៃបិដក អាចារ្យខ្លះជាអ្នកឲ្យឧបសម្បទា ខ្លះជាអ្នកពន្យល់ឲ្យបានសម្រេចមគ្គនឹងផល ក៏លោកគ្រូអាចារ្យទាំងនេះ ពិតមែនតែលោកបានបង្ហាត់ បង្រៀនបំណេះវិជ្ជា យ៉ាងឧត្តមយ៉ាងប្រសើរហើយ តែថាលោកទាំងនោះ គង់បង្ហាត់បង្រៀន ជាខាងក្រោយមាតាបិតានោះដែរ ហេតុនេះហើយ បានជាសម្ដេចព្រះឈ្មោះមារ ទ្រង់ត្រាស់ឲ្យឈ្មោះមាតាបិតានោះថា បុព្វាចារ្យ ឲ្យឈ្មោះអាចារ្យក្រៅពីនោះ ហៅថាបច្ឆាចារ្យ ។

នាមទី ៤ ដែលហៅថា អាហុនេយ្យា ។ នោះប្រែថា អ្នកទាំងឡាយឯណា ជាអ្នកមានសភាពដ៏សមគួរនឹងទទួលនូវវត្ថុទាំងពួង មានបាយនឹងទឹកជាដើម ដែលបុគ្គលតាក់តែងស្រេចហើយ នាំចូលមកជូន មកបូជា អ្នកទាំងនោះ បានឈ្មោះថាអាហុនេយ្យា អធិប្បាយថា មាតាបិតានេះ ជាបុគ្គលល្មមសមគួរនឹងទទួលនូវវត្ថុទាំងពួង មានបាយនឹងទឹកជាដើម ដែលកូនបាត់បែងស្រេចហើយ នាំចូលមកជូន មកបូជា ព្រោះថា មាតាបិតានេះ ជាអ្នកមានឧបការគុណបំពោះដល់កូន ព្រោះហេតុនេះហើយ បានជាព្រះទសពលញាណទ្រង់ប្រោសប្រទាននូវបទគាថា ទុកមកក្នុងព្រហ្មសូត្រ ក្នុងគម្ពីរអង្គុត្តរនិកាយ តិកបត្ថុកនិបាតបាៈ

ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកាតិ ។

សេចក្ដីថា លោកអ្នកមានគុណទាំងពីរនាក់គឺ មាតានឹងបិតានេះ ព្រះសព្វញ្ញុតញ្ញាណ ទ្រង់មានភាសិតសំដែងថា កូនប្រុស-ស្រីទាំងឡាយ គួរហៅមាតាបិតា នោះថា ព្រហ្មាផង ហៅថា បុព្វទេវាផង ហៅថា បុព្វាចារ្យផង នឹងហៅថា អាហុនេយ្យាផង ព្រោះអ្នកទាំងពីរនេះ លោកមានចិត្តស្រឡាញ់យ៉ាងស្និទ្ធ អនុគ្រោះដល់កូនប្រុស-ស្រីទាំងឡាយឥតមានស្រាកស្រាន្ត មាតាបិតានេះហើយ ដែលជាអ្នកបំរើនូវជីវិតដល់កូន ជាអ្នករក្សានូវជីវិតនៃកូន ជាអ្នកបន្តនូវជីវិតនៃកូនឲ្យប្រព្រឹត្តជាប់ទៅរឿយ ៗ ។

ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងថា មាតាបិតានេះ លោកមានឧបការគុណយ៉ាងច្រើន បំផុត ជារបស់ជាប់បំពោះទៅដល់កូនទាំងឡាយៗ មិនអាចធ្វើបដិការតបស្នងសងគុណលោកទាំងនោះ បានដោយងាយឡើយ មានសេចក្ដីសំដែងប្រៀប ទុកមកថា ប្រសិនណាបើកូនប្រុសឯណា មាន ចិត្តអាណិតស្រឡាញ់មាតាបិតានោះ ថាជាអ្នកដ៏ មានគុណច្រើន ហើយតាំងចិត្តថា អាត្មាអញនឹង ធ្វើកិច្ចទំនុកបំរុង សងគុណមាតាបិតារបស់អញ ហើយបានបាត់បែងធ្វើសក្ការបូជា ដល់អ្នកដ៏ ប្រសើរនោះជាយ៉ាងច្រើន មានជូនបាយ ទឹក ម្ហូប បំណី សំពត់ អាវ ជាដើម ដល់អ្នកទាំងនោះ មិន តែប៉ុណ្ណោះឡើយ បានទាំងអញ្ជើញមាតាឲ្យលោក

ឡើងជិះលើស្មាខាងស្តាំ អញ្ជើញបិតាឲ្យឡើងជិះ
លើស្មាខាងឆ្វេង ដើម្បីសម្រាកលំហែបិត្តអ្នកទាំង
ពីរនោះ ឲ្យសប្បាយ បានទាំងបាប់នួតប្របាប់
បណ្តើរផង ហើយបើមាតាបិតានោះ លោកត្រូវ
ការនឹងបន្ទោបង់នូវមូត្រ ឬ លាមកទៅលើស្មាខ្លួន
នោះ កូននោះក៏មិនមានធុញទ្រាន់អ្វីឡើយ តាំង
បិត្តដូចបិត្តមាតាបិតាដែលកាលពខ្លួនលេងនោះឯង
ឯអំពើដែលធ្វើបំរើយ៉ាងនេះ នោះកុំថាឡើយ ធ្វើ
តែត្រឹម ១ ខែ ឬ ១ ថ្ងៃ បើទុកជាធ្វើទៅដល់ ១
រយឆ្នាំក្តី ក៏គង់នៅមិនទាន់ប្រសើរនៅឡើយ
ព្រោះមិនទាន់បានឈ្មោះថា ជាអ្នកសងគុណនៅ
ឡើយ ។

ម្យ៉ាងទៀត កូនឯណាជាអ្នកមានរិទ្ធិអានុភាព

ច្រើន អាចនឹងលើកមាតាបិតារបស់ខ្លួន ឡើងឡើ
សោយរាជសម្បត្តិ ជាស្ដេចចក្រពត្រាធិរាជ ជ
ម្ចាស់ទ្វីបទាំង ៤ នោះក្តី ហើយលើកមាតា
ឡើងកាន់ទីជាអគ្គមហេសី នៃស្ដេចចក្រពត្រាធិរា
នោះក្តី បំណែកខាងកូនអ្នកសង្គ្រោះនោះ ក៏មិនទា
បានឈ្មោះថា អ្នកសងគុណមាតាបិតានោះនៅ
ឡើយ បានត្រឹមតែផលបំពោះខ្លួនកូន ដែលជាអ្ន
សង្គ្រោះនោះប៉ុណ្ណោះ ។

មានពាក្យសួរថា ចុះហេតុអ្វី បើកូនប្រុសគ្រ
បានធ្វើផលម្ល៉ោះហើយ ក៏នៅតែថា មិនទាន់បា
ឈ្មោះថា ជាអ្នកសងគុណនៅឡើយ ។

ឆ្លើយថា បានជាមិនទាន់បានឈ្មោះថា ជាអ្ន
សងគុណនៅឡើយនោះ ព្រោះកិច្ចការដែលកូ

ប្រុសស្រីទាំងឡាយ បានធ្វើទំនុកបំរុងយ៉ាងនេះ បានគ្រាន់តែជាការសមគួរ ជាហេតុនាំឲ្យមាតាបិតា បានស្រួលកាយ ស្រួលចិត្ត តែក្នុងបច្ចុប្បន្ននេះម្យ៉ាង វេលាដល់មាតាបិតាទទួលមរណភាពទៅកាន់លោកខាងមុខទៀត មិនទាន់មានគុណសម្បត្តិអ្វីជាគ្រឿងឧបត្ថម្ភទំនុកបំរុងអំពីកូនធ្វើឲ្យនោះ ជួយជូនទៅផងនៅឡើយ លុះតែកូនឯណា ១ បានដឹងថា មាតាបិតារបស់ខ្លួននេះ នៅប្រកបដោយអកុសលធម៌ទាំងឡាយច្រើន មានមិនមានសទ្ធាជាដើម ឬ ដឹងថា ម្ដាយអាពុករបស់ខ្លួននោះបានប្រកបដោយគុណសម្បត្តិបរិបូណ៌ហើយ បើប្រសិនជាអ្នកទាំង ២ នោះ នៅប្រកបដោយអកុសលនៅឡើយ ហើយកូនទាំងនោះ អាច

លើកដឹកល់អ្នកមានគុណទាំងអម្បាលនោះ ឲ្យស្ថិតនៅក្នុងសម្បទាទាំង ៤ ប្រការ មានសទ្ធាសម្បទា ជាដើម ទើបកូនទាំងនោះ នឹងបានឈ្មោះថាជាអ្នកបានធ្វើបដិការ តបស្នងសងគុណលោកទាំងនោះបានជាស្រេច មិនបាច់ព្រួយទៅខាងមុខទៀតឡើយ ។

ឯសេចក្ដីដែលសំដែងមកខាងលើនេះ ត្រូវគ្នានឹងព្រះពុទ្ធភាសិត ដែលទ្រង់ទេសនាទុកក្នុងមាតាបិតុគុណសូត្រ ក្នុងគម្ពីរអង្គុត្តរនិកាយ ទុកនិបាតនោះថា ទ្វិន្នាហំ ភិក្ខវេ ន សុបដិការំ វទាមិ សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលថា កិរិយាដែលកូនប្រុស-ស្រី នឹងធ្វើតបគុណដល់មាតាបិតាទាំងពីរនោះ បានដោយងាយទេ គឺជាកិច្ច

ដែលកូនទាំងឡាយ បំរុងនឹងសងគុណអ្នកទាំងពីរនោះ បានដោយកម្រពេកណាស់ ដូចមានបទបាលីក្នុងមាតុគុណសូត្រនោះថា :

ឯកេន ភិក្ខវេ អំសេន មាតរំ បរិហរេយ្យ
ឯកេន អំសេន បិតរំ បរិហរេយ្យ វស្ស
សតាយុកោ វស្សសតជីវី ។ល។ បដិកតំ ភ ។

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើមានកូនណា ១ ដែលជាកូនប្រកបដោយកតញ្ញូ-ធម៌ បំរុងនឹងធ្វើបដិការគុណដល់មាតាបិតាទាំងពីរនោះ ហើយបានលើកស្ពាយនូវមាតានោះឲ្យស្ថិតនៅលើស្មាម្ខាង (១) បានលើកនូវបិតានោះ

---

១ ក្នុងបាលីមាតាបិតុគុណសូត្រប្រាប់ថា ឲ្យដំកល់មាតាលើស្មាម្ខាង បិតាលើស្មាម្ខាង ដល់ទៅក្នុងអដ្ឋកថា ទំងដីកាគម្ពីរនោះប្រាប់ថា ឲ្យដំកល់ម្តាយលើស្មាស្តាំ អាពុកលើស្មាឆ្វេង ។

ឲ្យស្ថិតនៅលើស្មាម្ខាង ហើយបានទាំងបែរក្បា
នូវអ្នកទាំងនោះ ដោយកិច្ចទាំងឡាយច្រើនយ៉ាង
មានផ្ចិតទឹក ដុសក្អែល លាបស្រឡាបដោយ
គ្រឿងក្រអូប ដើម្បីបំបាត់នូវក្លិនអាក្រក់ចេញ និង
ចាប់ន្លួតគាស់សរសៃជាដើម សព្វ ៗ វេលាដែលគួរ
ធ្វើ បើប្រសិនជាអ្នកមានគុណទាំងពីរនោះ កាល
ដែលនៅលើស្មារបស់ខ្លួននោះហើយ មានកិច្ច
ត្រូវបន្ទោបង់នូវទុកសាត់តូចធំលើស្មាខ្លួននោះ ក៏
កូននោះឥតមានចិត្តអាក់អន់ដល់តិចឡើយ ប៉ុន្តែ
ទទួលធ្វើកិច្ចទាំងនោះ មិនមានធុញទ្រាន់នឿយ
ណាយដល់តិចឡើយ ។

ឯអំពើដែលកូនបានធ្វើយ៉ាងនេះ ជាអំពើ
យ៉ាងឧត្តមសមគួរ របស់កូនជាទីបំផុតណាស់

ហើយនឹងរកកិច្ចអ្វីដទៃ ឲ្យប្រពៃក្រៃលែងជាងនេះទៀតគ្មាន ឯអំពើដែលធ្វើយ៉ាងនេះ កុំថាធ្វើត្រឹម ១០ ថ្ងៃ ឬ ១០ ឆ្នាំ បើទុកជាធ្វើដរាបដល់ ១០០ ឆ្នាំ ឬ ១ ជីវិតរបស់ខ្លួនក្តី ក៏គង់មិនទាន់ឲ្យឈ្មោះដល់អ្នកដែលធ្វើនោះ ថាជាអ្នកបានតបស្នងសងគុណមាតាបិតានោះនៅឡើយ នែភិក្ខុទាំងឡាយ កុំថាឡើយ កូនទាំងពួងនោះបានធ្វើកិច្ចទំនុកបំរុងមាតាបិតា ដូចពណ៌នាមកនេះ ទុកជាកូនទាំងនោះ មានអានុភាពអាចនឹងលើកអ្នកដ៏មានគុណទាំងពីរនោះ ឲ្យសោយរាជសម្បត្តិ ជាស្តេចចក្រពត្រាធិរាជ ជាឥស្សរាធិបតី ប្រកបដោយសិរីសម្បត្តិដ៏ប្រសើរ ឥតបីជនណានឹងប្រៀបបានក្តី នែភិក្ខុទាំងឡាយ កិច្ចដែលកូនទាំងនោះ

បានលើក បានស្ទួយ ដំកើងនូវអ្នកទាំងពីរនោះ ឲ្យស្ថិតនៅក្នុងសិរីសម្បត្តិ មហាប្រសើរយ៉ាងនេះ ហើយ ក៏នៅមិនទាន់ធួនល្មមដល់គុណនៃមាតា បិតាដ៏ប្រសើរនោះទេ ។

ពាក្យសួរថា ឯសេចក្តីសុខ នឹងកេរ្តិ៍ឈ្មោះរបស់ មនុស្សក្នុងលោកនេះ ក៏ផុតត្រឹមសម្បត្តិស្តេចចក្រ ពត្រាធិរាជនេះហើយ ឥឡូវបើកូនទាំងនោះ បាន ជូន បានបូជានូវសម្បត្តិទាំងនោះ ដល់អ្នកវិសេស ទាំងពីរនោះហើយ ៗ ថា នៅតែមិនទាន់ធួនល្មម ដល់គុណ មិនបានឈ្មោះថា ជាអ្នកធ្វើកតញ្ញូ កតវេទីនៅឡើយនោះ តើព្រោះហេតុអ្វី ។

ពាក្យឆ្លើយថា ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់សំដែង ថា នែភិក្ខុទាំងឡាយ មិនមែនព្រោះហេតុអ្វីទេ

គឺព្រោះតែព្រះជននិកា និងព្រះជននិកោ ទាំងពីរនោះ លោកមានឧបការគុណជាទម្ងន់ធ្ងន់ណាស់ ដល់កូននោះប៉ុណ្ណោះឯង ព្រោះថា អ្នកទាំងពីរនោះ ជាអ្នកអាចបង្កើតកូនឲ្យកើតឡើងផង ហើយអាចបេះស្រោបស្រង់បំរុងបំរើននូវជីវិត ឲ្យដល់កូននោះផង ជាអ្នកបន្តនូវសេចក្តីរស់ស្រស់ ឲ្យកូននោះផង ជាអ្នកបង្ហាញនូវវត្តក្នុងលោកនេះ ឲ្យកូនបានដឹង បានស្គាល់សព្វគ្រប់ផង ជាអ្នកបិត្បំរាក្សាកូនដោយធម៌ព្រហ្មវិហារទាំង ៤ ប្រការ មានមេត្តាព្រហ្មវិហារ ជាដើមផង ជាទេវតារក្សាកូនមុនជាងទេវតាទាំងពួងផង ជាអាចារ្យបង្ហាត់បង្ហាញកូន មុនជាងអាចារ្យទាំងពួងផង ជាភ្ញៀវយ៉ាងឧត្តម គួរកូនបូជាជាងភ្ញៀវទាំងពួងផង ព្រោះ

ហេតុប៉ុណ្ណោះជាដើមហើយ បានជាតថាគតសំដែងថា មាតាបិតាមានឧបការគុណជាទម្ងន់ដល់កូនជាទីបំផុត ហើយព្រះសម្ពុទ្ធទ្រង់ភាសិតតទៅទៀតអំពីធម៌ដែលកូនត្រូវសងគុណដល់មាតាបិតា ឲ្យបានគ្រប់គ្រាន់រួចបាកបំណុល គឺគុណនោះថា :

យោ ច ខោ ភិក្ខវេ មាតាបិតរោ អសទ្ធេ សទ្ធាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ទុស្សីលេ សីលសម្បទាយ មច្ឆរិនោ ចាគសម្បទាយ ទុប្បញ្ញេ បញ្ញាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ឯត្តាវ ខោ ភិក្ខវេ មាតាបិតូនំ កតញ្ច ហោតិ បដិកតញ្ច អតិកតញ្ចាតិ ។

សេចក្តីថា នែភិក្ខុទាំងឡាយ បើកូនប្រុសស្រី

ណា១ មានចិត្តប្រកបដោយកតញ្ញូធម៌ បានណែនាំនូវមាតាបិតានោះ ឲ្យដឹកលំនៅក្នុងគុណសម្បទ ឬ បានបបួលពន្យល់ លើកដំកល់នូវជនិកាជនិកោ ទាំងពីរនោះ ដែលមិនទាន់មានសទ្ធាជ្រះថ្លា ឲ្យតាំងនៅក្នុងសទ្ធាសម្បទា ១ ដែលមិនទាន់មានសីល ឲ្យស្ថិតនៅក្នុងសីលសម្បទា ១ ដែលជាអ្នកកំណាញ់ ឲ្យដឹកលំនៅក្នុងចាគសម្បទា ១ ដែលជាអ្នកល្ងង់ខ្លៅអាប់ឥតប្រាជ្ញា ឲ្យតាំងនៅក្នុងបញ្ញាសម្បទា ១ នៃភិក្ខុទាំងឡាយ បើកូនប្រុសស្រីណា ១ បានសង្គ្រោះទំនុកបំរុងនូវមាតាបិតាឲ្យបានប្រកបដោយធម៌ ៤ ប្រការនេះហើយ កូនប្រុសស្រីនោះ បានឈ្មោះថា ជាអ្នកសងគុណ ឬ តបគុណ ឬ ជាអ្នកសងគុណក្រៃពេក គឺថា

ជាផលកតញ្ញូអ្នកកតវេទី មាតាបិតា ឈ្មោះថា ជាអ្នកសងគុណហើយជាស្រេច ឥតមានជំពាក់បំណុលទៀតឡើយ ។

ធម៌សម្រាប់សងគុណទី៖ ១ អធិប្បាយថា បើអ្នកដ៏មានគុណទាំងពីរនោះ ជាមនុស្សមិនទាន់មានសទ្ធាជ្រះថ្លានៅឡើយ គឺមិនទាន់មានចិត្តប្រកបដោយសទ្ធាចេតសិក គឺមិនទាន់ជឿកម្មនឹងផលនៃកម្ម មិនស្គាល់បុណ្យបាប មិនចូលចិត្តថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប មិនទាន់ចូលចិត្តថា បើខ្លួនធ្វើអាក្រក់ សេចក្ដីអាក្រក់ទាំងនោះ នឹងត្រឡប់បានមកខ្លួនវិញ បើខ្លួនធ្វើល្អប្រព្រឹត្តល្អ សេចក្ដីល្អនោះ នឹងវិលបានមកខ្លួនវិញមិនខាន ។

បំណែកខាងកូនប្រុសស្រី ក៏អាចនឹងនិយាយពន្យល់ ណែនាំនូវមាតាបិតានោះ ឲ្យមានចិត្តជឿបុណ្យ ជឿបាប ឲ្យបានជាកល់ខ្លួនអ្នកទាំងពីរនោះទៅក្នុងសទ្ធាសម្បទា ដោយសប់សួនតិតង៉ាករេ បើអ្នកទាំងពីរនោះ ស្ដាប់បាន ជឿចូលចិត្តដោយពាក្យប៉ុណ្ណោះទៅក៏ជាការល្អប្រពៃពេក បើប្រសិនជាអ្នកទាំងនោះ មិនអាចជឿបានទេ គឺនៅមានសង្ស័យនៅឡើយ នោះកូនប្រុសស្រីគួរគប្បីអញ្ជើញយកព្រះពុទ្ធភាសិត ដែលទ្រង់សំដែងអំពីគុណសទ្ធា គុណសីល គុណបរិច្ចាគ នឹងគុណបញ្ញាទុកក្នុងគម្ពីរផ្សេងៗ មានគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាតជាដើម មកសំដែងពន្យល់ដល់អ្នកមានគុណទាំងនោះ ដរាបទាល់តែជឿចូលចិត្តស្ដាប់បាន ។

ម្យ៉ាងទៀត អដ្ឋកថាមាតាបិតុគុណសូត្រដីកាទុកង្គុត្តរនិកាយ និងដីកាវិសុទ្ធិមគ្គ មានសេចក្តីសំដែងអំពីការគោរពប្រតិបត្តិ បំរើនូវមាតាបិតាតទៅទៀត ដូចមានសេចក្តីខាងក្រោយនេះ ។

ឯពាក្យដែលថា គោរពប្រតិបត្តិបំរើនោះ គឺធ្វើនូវសក្ការបូជាដល់មាតាបិតា និងនមស្សការថ្វាយបង្គំនូវអ្នកទាំងពីរដោយគោរព ទើបបានឈ្មោះថា គោរពប្រតិបត្តិបំរើនូវមាតាបិតា ព្រោះហេតុនេះហើយ បានជាព្រះសព្វញ្ញុតញ្ញាណ ទ្រង់ប្រោសប្រទាននូវធម៌ទេសនា ជាបទគាថាទុកមកក្នុងសោណនន្ទជាតក ក្នុងសព្រហ្មកសូត្រ ថាដូច្នេះ:

តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យ ប
បណ្ឌិតោ អន្នេន អហោ បានេន វត្ថេន

សយនេន ច ឧច្ឆាទនេន នហាបនេន ច
បាទានំ ធោវនេន ចាតិ ។

សេចក្ដីថា មនុស្សដែលជាបណ្ឌិតជាតិ គួរគប្បីធ្វើនូវសេចក្ដីគោរពរាប់អាន ឧមស្សការនូវមាតាបិតាទាំងឡាយ និងធ្វើសក្ការបូជាដោយវត្ថុទាំងឡាយ មានបាយ និងទឹក សំពត់ ទីដំណេក គ្រឿងអប់ គ្រឿងងូត និងទឹកសម្រាប់លាងជើងជាដើម ដល់មាតាបិតាទាំងឡាយនោះ ។

ឯពាក្យដែលហៅថា ឧមស្សការនោះ អធិប្បាយថា កូនប្រុស-ស្រីដែលជាអ្នកមានប្រាជ្ញា មានប្រាថ្នានូវសេចក្ដីចំរើន គប្បីចូលទៅកាន់ទីជិតនៃមាតាបិតា បំរុងខ្លួនជាអ្នកបំរើរាល់ពេលព្រឹកល្ងាច ហើយគប្បីឧមស្សការដោយតាំងចិត្តថា ឯការ

ដែលខ្លួនអញបានគោរពប្រតិបត្តិ បំរើនូវមាតាបិតា នេះ ជាបុញ្ញក្ខេត្តយ៉ាងឧត្តមរបស់អញហើយ ។

ពាក្យដែលថា ធ្វើសក្ការបូជានោះ អធិប្បាយថា កូនប្រុស-ស្រីទាំងឡាយ ទោះគ្រហស្ថក្តី អ្នកបួសក្តី ត្រូវជូន ឬ បូជានូវភោជនាហារទាំងឡាយ មានបបរ នំបាយ នំគ្រឿងស៊ី គ្រឿងលេប ជាដើម ដល់មាតាបិតារបស់ខ្លួនតាមវត្តិបប្រើន នឹងបាត់បែងនូវទឹកអដ្ឋបានទាំងឡាយ ៨ ប្រការ មានទឹកចេក ទឹកស្វាយជាដើម ដល់ម្តាយអាពុក នឹងជូននូវសំពត់សម្រាប់ស្លៀកដណ្តប់ នឹងអាវសម្រាប់ពាក់ផង ត្រូវធ្វើនូវទីសម្រាប់ដេកនឹងអង្គុយ គឺគ្រែ ឬតាំង សម្រាប់អ្នកមានគុណទាំងនោះ ត្រូវដេក ឬអង្គុយក៏បាន ហើយស្វែងរកគ្រឿងក្រអូប យក

មកអប់នូវទីដេក ទីអង្គុយ នឹងសំពត់អាវរបស់មាតាបិតាទាំងនោះ ឲ្យក្រអូប ដើម្បីនឹងបំបាត់ក្លិនអាក្រក់ជូរផ្អូមចោលចេញ បើក្នុងរដូវត្រជាក់ ត្រូវរកទឹកក្តៅមកជូនឲ្យងូតឲ្យផឹក ហើយត្រូវដំកល់ទុកជូន បើក្នុងរដូវក្តៅ ត្រូវឲ្យនូវទឹកត្រជាក់សម្រាប់ងូតនឹងផឹក ហើយត្រូវដំកល់នូវទឹកសម្រាប់លាងដៃ លាងជើង ឲ្យមាននៅជានិច្ចផង ត្រូវប្រកបកិច្ចបំរើរក្សាទាំងឡាយ មាននួតប្របាច់ ចាប់សរសៃតាមជើង តាមដៃជាដើម ជូនលោកអ្នកមានគុណទាំងនោះ ក្នុងកាលដែលលោកមិនសប្បាយនោះផង ។

ឯការគោរពប្រតិបត្តិបំរើមាតាបិតានោះ ត្រូវអ្នកបួស ឬ គ្រហស្ថធ្វើបានដូចគ្នា តែបើលោកអ្នកបួស

ជាភិក្ខុ ត្រូវធ្វើសក្ការបូជា នឹងការបំរើគ្រប់បំពូក បានទាំងអស់ លើកតែត្រង់នមស្សការថ្វាយបង្គំ នឹងចាប់កាន់ផ្ទាល់ដល់កាយនៃមាតានោះ មិនគួរធ្វើឡើយ បើមាតាទៅកាន់ទីវត្តដែលខ្លួននៅនោះ កូនជាអ្នកបួស ត្រូវធ្វើកិច្ចបំរើគ្រប់បំពូក មានជូនភោជនាហារឲ្យពិសាជាដើម ដោយដៃខ្លួនឯងបាន តែកុំចាប់ពាល់ឲ្យត្រូវកាយមាតានោះ ។ បំណែកខាងបិតាវិញ បើកូននោះជាភិក្ខុ ត្រូវបំរើបិតានោះបានគ្រប់បំពូក ឥតមានហាមបំពូកណា ១ ឡើយ ដូចសាមណេរបំរើភិក្ខុនោះឯង ។

លោកអ្នកបួសជាភិក្ខុ ប្រសិនបើបានឃើញមាតានោះមានគ្រោះថ្នាក់ ធ្លាក់ក្នុងប្រឡាយទឹកជ្រៅ ហែលតាមខ្សែទឹកនោះទៅ កុំអាលស្ទុះទៅ

ចាប់មាតាផ្ទាល់ដោយដៃខ្លួនឡើយ តាមវិន័យបញ្ញត្តិថា ត្រូវឲ្យរកទូក ឬ ផែនក្ដារ ដើមបោកកំណាត់ឈើស្ងួត ហុចទៅត្រង់ទីបំពោះមុខនៃមាតានោះ កាលបើមិនមានវត្ថុទាំងនោះនៅជិតដៃទេ លោកថា ត្រូវហុចសំពត់ង្ហូត ឬ ចីវររបស់ខ្លួនទៅមាតា តែកុំពោលថា ញោមចូរកាន់យកនូវសំពត់នេះឡើយ កាលបើមាតានោះបានតោងចាប់សំពត់ចីវរនោះជាប់ហើយ ត្រូវទាញមកដោយស្រួល ហើយធ្វើទុកក្នុងចិត្តថា អាត្មាអញទាញយកនូវសំពត់ចីវររបស់អញទេ បើប្រសិនជាម្ដាយមានចិត្តភិតភ័យខ្លាចខ្លាំង ខ្លួនភិក្ខុនោះ ត្រូវហែលនាំទៅខាងមុខ ហើយនិយាយលួងលោមញោមនោះបណ្ដើរ ដោយពាក្យពីរោះថា ញោមកុំភ័យ

ភិតឡើយ មិនអីទេ ម៉ាបើមាតានោះ មានសេចក្តី ភ័យខ្លាំងទប់ពុំបាន ស្រែកស្ទុះមកចាប់ឱបក្រសោប លោកភិក្ខុនោះ ចំណែកលោកជាភិក្ខុ កុំឃាត់ខាំង រាំងរាគះចេញឡើយ ត្រូវបណ្ដោយតាមចិត្តម្ដាយ ចង់ចាប់ដៃ ឬ ខ្លួនក៏បាន ត្រូវនាំមាតានោះទៅឲ្យ ដល់លើគោក រកទីឲ្យស្រួល ឲ្យមាតាស្ថិតនៅ មិនមានទោសអ្វីទេ ។

ម្យ៉ាងទៀត បើមាតានោះជាប់ភក់ ឬ ធ្លាក់ទៅ ក្នុងរំលុងអណ្ដូង ភិក្ខុត្រូវទំលាក់ខ្សែ ឬ គសំពត់ ហុចសំយុងចុះទៅ បើមាតានោះ បានចាប់កាន់ ជាប់មាំមួនហើយ ភិក្ខុនោះ ត្រូវប្រឹងយោងមាតា ឡើង ឲ្យរួចផុតពីទីនោះឲ្យបាន តែលោកថា កុំ ឲ្យចាប់ផ្ទាល់ដល់ខ្លួនមាតានោះឡើយ បើប្រសិន

ណាជាបាប់កាន់ទៅក៏មិនជាការអ្វីដែរ គ្រាន់តែថា មិនគួរប៉ុណ្ណោះឯង ។

ម្យ៉ាងទៀត ភិក្ខុគួរគប្បីនឹងផ្សំភេសជ្ជ គឺថ្នាំសម្រាប់កែរោគ ឬ រំងាប់រោគ ជូនមាតាបិតាបានឥតមានទោស មិនបានឈ្មោះថា វេជ្ជកម្មទេ គួរជូននូវអនាមដ្ឋបិណ្ឌបាត គឺអាហារបិណ្ឌបាត ដ៏ហ៊ុង ដ៏ប្រសើរ ដ៏មានដំឡៃ ដល់មាតាបិតាបាន មិនមែនញ៉ាំងសទ្ធារបស់ទាយកអ្នកឲ្យនោះ ឲ្យវិនាសឡើយ ឯមាតាបិតានោះ បើភិក្ខុនឹងឲ្យនូវវត្ថុទាំងឡាយ មានសំពត់ជាដើម ក៏គួរទាំងអស់ ឥតមានហាម ដូចមាននិទានក្នុងអដ្ឋកថាមង្គលសូត្រសំដែងថា ក្នុងសម័យមួយនោះ មានភិក្ខុមួយអង្គមាននាមមិនប្រាកដ ភិក្ខុនោះ មានសំពត់ចីវរ·

ច្រើនមិនបរិបូណ៌ពេកណាស់ចុះ មានប្រាថ្នានឹងឲ្យទៅមាតាបិតារបស់ខ្លួន តែក្នុងវេលានោះ មានភិក្ខុទាំងឡាយច្រើនរូប បានដឹងសេចក្តីនោះហើយក៏ចូលទៅក្រាបបង្គំទូលព្រះបរមសាស្តា តាមហេតុនោះ ឯព្រះបរមសាស្តា ស្តេចក៏ទ្រង់មានពុទ្ធភាសិតថា នែភិក្ខុទាំងឡាយ បើភិក្ខុនោះមានប្រាថ្នានឹងឲ្យនូវសំពត់ចីវរទៅមាតាបិតារបស់ខ្លួននោះ គួរតែឲ្យទៅឥតមានទោសទេ ទើបទ្រង់អនុញ្ញាតទុកមក ថាដូច្នេះ ;

អនុជានាមិ ភិក្ខវេ មាតាបិតូនំ ទាតុំ ន ប ភិក្ខវេ សទ្ធាទេយ្យំ វិនិបាតេតព្វំ យោ វិនិបាតេយ្យ អាបត្តិ ទុក្កដស្ស ។

សេចក្ដីថា នែភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុទាំងឡាយ ឲ្យនូវសំពត់ចីវរទាំងឡាយ ដល់មាតាបិតាបាន មិនមានទោស ម្នាលភិក្ខុទាំងឡាយ ឯកិច្ចដែលភិក្ខុនឹងឲ្យនូវវត្ថុដល់មាតាបិតានោះ មិនមែនធ្វើនូវសទ្ធារបស់ទាយកជាអ្នកឲ្យនោះ ឲ្យវិនាសខូចទេ បើភិក្ខុឯណា អាចញុំាងសទ្ធារបស់ទាយកដែលជាអ្នកឲ្យនោះ ឲ្យធ្លាក់ខូច ភិក្ខុនោះ នឹងត្រូវអាបត្តិទុក្កដមិនលែង ។ ហេតុដូច្នេះ ទោះអ្នកបួសក្តី គ្រហស្ថក្តី ត្រូវតែគោរពប្រតិបត្តិបំរើនូវមាតាបិតា តាមកិច្ចដ៏សមគួរដល់វិន័យបញ្ញត្តិ កុំធ្វេសប្រហែសឡើយ ជំនុំអ្នកបួស នឹងគ្រហស្ថទាំងពីរពួកនេះ បើអ្នកណា ១ ប្រព្រឹត្តឲ្យខុសនឹងមាតាបិតា គឺប្រមាថមើលងាយ ហើយអ្នក

នោះ នឹងដល់នូវសេចក្តីទុក្ខយ៉ាងធំមិនខាន ដូចជាជនទាំងឡាយច្រើនរូប មានជនឈ្មោះ មិត្តវិន្ទុកជាដើម ៗ

ឯរឿងមិត្តវិន្ទុកបុរសនោះ មានមកក្នុងអដ្ឋកថា នៃចតុទ្វារជាតក ក្នុងទសនិបាត ដូចមានខាងក្រោយនេះ ៖

បានដឹងដំណឹងប្រាកដមកថា ក្នុងសម័យមួយនោះ មានសេដ្ឋីម្នាក់ មានទ្រព្យ ៨០ កោដិ ទីលំនៅៗ ទៀបក្រុងពារាណសី ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា កស្សប ។ ឯសេដ្ឋីនោះ មានកូនប្រុសម្នាក់ឈ្មោះថា មិត្តវិន្ទុក កូននោះជាមនុស្សគ្មានសទ្ធាជ្រះថ្លា ហើយថែមទាំងគ្មានសីលផង ឯមាតាបិតាទាំងពីរនោះ ជាពុទ្ធមាមកៈ ជា

អ្នករាប់អានព្រះពុទ្ធជាម្ចាស់ ហើយជនទាំងនោះ
បានដល់នូវព្រះសោតាបត្តិផលផង ក្នុងវេលាមួយ
បិតាក៏ទទួលមរណភាពទៅកាន់លោកខាងមុខ នៅ
តែមាតានឹងកូនប្រុសនោះឯង ឯកូននោះ មានចិត្ត
ចង់ទៅរកលក់ដូរជួញប្រែដោយសំពៅ ទៅស្រុក
ឆ្ងាយ ទើបចូលទៅលាម្តាយនោះថា នែម៉ែ ខ្ញុំត្រូវ
ការចង់ទៅជួញប្រែនឹងគេដោយសំពៅ ឯម្តាយនោះ
ពុំចង់ឲ្យកូនទៅ ព្រោះមានកូនតែមួយ ហើយ
ក៏ឃាត់កូននោះថា ហៃកូនស្ងួនសំឡាញ់របស់
ម្តាយតែមួយ ចូរកូនកុំទៅ ម្តាយមិនព្រមឲ្យអ្នក
ទៅទេ កូនអើយ ឯមហាសមុទ្រនោះ មិនមែន
សប្បាយទេ ទីនោះប្រកបដោយសេចក្តីភ័យ
អន្តរាយច្រើនប្រការពេកណាស់ ម្យ៉ាងទៀត ទ្រព្យ

ក្នុងផ្ទះរបស់យើងគមានទៅច្រើនហើយ កូនឯង ចាយវាយធ្វើអ្វីក៏បាន ឥតមានខ្វះខាតទេ ចូរកូនកុំទៅ ឯមិត្តវិន្ទកជាកូននោះ មិនទទួលស្ដាប់ពាក្យម្ដាយនោះឡើយ ហើយក៏ក្រោកឡើងដើរចេញទៅ ពោលពាក្យថា ម៉ែកុំឃាត់ខ្ញុំ ៗ មិនស្ដាប់ម៉ែឯងទេ ខ្ញុំចេះតែទៅ ទើបមាតាក៏ចាប់ដៃកូននោះទាញមកវិញ ឯកូនក៏រលាស់ដៃនោះផុតចេញ ហើយប្រហារមាតានោះនឹងកំឡាំងដៃយ៉ាងធ្ងន់ មាតាក៏ដួលដេកទៅលើផែនដីនៅមុខកូន ៗ នោះក៏លោតកន្លងលើម្ដាយ ហើយរត់ទៅ ដម្រង់ទៅឡើងជិះសំពៅ រួចបើកចេញទៅ លុះសំពៅបើកទៅដល់កណ្ដាលសមុទ្រ ក៏ស្រាប់តែជាប់គៀងនៅនឹង ឥតមានកំរើក នៅយូរអស់ប្រមាណជា ៧ ថ្ងៃ ទើបអ្នក

សំពៅទាំងអស់គ្នា ប្រជុំគ្នាគិតពិចារណារកហេតុ
ដែលកឿងសំពៅនោះ ទើបឃើញសេចក្តីថា មុខ
ជាមានមនុស្សអាក្រក់កាឡកណ្ណី មាននៅក្នុង
សំពៅនេះមិនខាន ក៏អ្នកសំពៅទាំងនោះ ចាត់
ចែងចែកស្លាកឲ្យចាប់ លុះចាប់ស្លាកទៅហើយ
ស្លាកដែលអាក្រក់នោះ ក៏ត្រូវទៅលើចៅមិត្តវិន្ទុក
ដែលជាអ្នកប្រទុស្តនូវមាតា ហើយរត់ចុះសំពៅមក
នោះគ្រប់ ៣ ដង ទើបមនុស្សទាំងអស់ធ្វើក្បូន
ហើយ ចាប់ខ្លួនចៅមិត្តវិន្ទុកដាក់ទៅលើក្បូននោះ
ហើយបន្សាត់ទៅតាមខ្សែទឹក ទៅក្នុងសមុទ្រធំ
នោះ ឯចៅមិត្តវិន្ទុកនោះ លុះទៅដោយក្បូននោះ
បានតិចទៅ ក៏បានដល់កោះមួយ ហើយឡើងទៅ
លើកោះនោះ ទើបបានឃើញនគរ ១ ធំមាំមួន

ប្រកបដោយទ្វារ ៤ ប្រការ ឯនគរនោះ មិនគឺ
ស្រុកណា គឺឋាននរកដែលឈ្មោះថា ឧស្សុទនរក
នោះឯង មានសត្វដែលសោយទុក្ខវេទនាក្នុងទី
នោះជាច្រើន បំណែកឯចៅមិត្តវិន្ទុកបានឃើញនូវ
ទីនរក ដែលអាក្រក់ជាបំផុតនោះ ក៏ត្រឡប់ជា
ឃើញល្អស្អាតបរិសុទ្ធ គួរជាទីជ្រះថ្លាទៅវិញ
ព្រោះកំឡាំងនៃផលបាប ដែលខ្លួនប្រហារទះតប់
នូវមាតានោះ បណ្ដាលឲ្យឃើញនូវទីអាក្រក់
ត្រឡប់ទៅជាស្ថានល្អវិញ ហើយធ្វើទាំងគំនិតចិត្ត
ស្មារតី ឲ្យភាន់ភាំងគិតខុសប្រក្រតីអស់ទៅវិញ ឯ
ចៅមិត្តវិន្ទុក ក៏ដើរចូលទៅក្នុងទីនរកនោះ ដោយ
គំនិតថា មុខជាមានព្រះមហាក្សត្រ ស្ដេចសោយ
រាជសម្បត្តិក្នុងក្រុងនោះមិនលែង លុះចូលទៅ

ហើយ ក៏បានឃើញសត្វនរកម្នាក់ ទូលនូវកងចក្រ មានមុខមុតដូចជាកាំបិតកោរ កំពុងវិលចាក់ផ្ដៀល នូវអម្បែងក្បាលនៃសត្វនរកនោះ សត្វនោះបាននូវសេចក្ដីវេទនាទុរន់ទុរាក្រៃពេក ឯចៅមិត្តវិន្ទុកបានឃើញកងចក្រ ដែលមុតជាប់លើក្បាលនៃសត្វនរកនោះ ក៏ប្រាកដថាជាផ្កាឈូកក្រពុំធំ ស្ថិតនៅលើក្បាលនៃសត្វនរកនោះ ឯចំណង ៥ ប្រការ ដែលនិរយបាល ចងព័ទ្ធជាក់រឹតរួតនូវដើមទ្រូងនៃសត្វនរកនោះ ក៏ឃើញប្រាកដដូចជាគ្រឿងមហាលតាបសាធន ដ៏ល្អភ្លឺផ្លេកដូចជាសង្វារមាសពាសព័ទ្ធនូវដើមទ្រូង គួរឲ្យជាទីជ្រះថ្លាក្រៃពេក បានឃើញឈាមដែលហូរបេញអំពីសរីរាងកាយនៃសត្វនរកនោះ ក៏ប្រាកដហាក់ដូចជាគ្រឿងលាប

ដោយខ្លឹមប័ន្ទន៍ក្រហមរះពាសពេញទាំងខ្លួននៃសត្វ
នរកនោះ ។ បានឮនូវសំឡេងនៃសត្វនរកស្រែក
ទ្រហោយំនោះ ក៏ប្រាកដដូចជាសំឡេងច្រៀង
ប្រឡែងលេងដោយសប្បាយ ។ ឯមិត្តវិន្ទុកបុរស
នោះ បានឃើញដូច្នោះហើយ ក៏មានសោមនស្ស
ចេតនា ប្រាថ្នាចង់ទ្រទ្រង់នូវផ្កាឈូក ជាគ្រឿង
ប្រដាប់ទាំងនោះក្រៃពេក នឹងទប់ទល់ពុំបាន ទើប
ដើរចូលជិតនៃសត្វនរកនោះ ហើយនិយាយថា
នែអ្នកដ៏បំរើន សូមអ្នកអាណិតខ្ញុំ សុំអ្នកឲ្យនូវផ្កា
ឈូកជាគ្រឿងប្រដាប់ ដែលអ្នកទ្រទ្រង់មកយូរ
ហើយនោះមកខ្ញុំ ៗ នឹងបានទ្រទ្រង់លេងផងកុំ
ខាន ។ ឯសត្វនរកនោះ ក៏ប្រាប់មកវិញថា ឱ
សំឡាញ់អើយ មានផ្កាឈូកឯណា មិនមែនទេ

គឺកងបក្រមានមុខមុតដូចដុះខកាំបិតកោរ  កំពុងតែ
បាក់បោះក្បាលខ្ញុំឈឺខ្លាំងណាស់សំឡាញ់ ៗ ឯ
មិត្តវិន្ទុកក៏ឆ្លើយទៅវិញថា  អើព្រោះតែអ្នកមិនបង់
ឲ្យខ្ញុំហើយ  បានជាអ្នកឋាដូច្នេះ កងបក្រឯណា បើ
ខ្ញុំឃើញជាក់ប្រាកដជាផ្កាឈូកហើយនេះ  ទើប
សត្វនរកនោះ  មកគិតក្នុងចិត្តថា  ផលកម្មរបស់
អញ ប្រហែលជាអស់ហើយដឹង  បានជាបណ្ដាល
ឲ្យគេឃើញយ៉ាងនោះវិញ  ឯអ្នកនេះ ទំនងជាអ្នក
ប្រទូស្តមាតា ប្រហារមាតាដូចជាអញដែរដឹង ទើប
មកបង់ទទួលវេរានេះអំពីអញនេះឯង  បើដូច្នោះ
គួរអញនឹងលើកកងបក្រនេះ ឲ្យទៅបុរសនេះល្បង
មើល ៗ លុះគិតយ៉ាងនេះហើយ  ក៏ហៅមិត្តវិន្ទុក
នោះឲ្យចូលមកជិត  ហើយក៏លើកកងបក្រនោះ

បំពាក់ទៅលើក្បាលឲ្យ ៖ ឯក្អមក្របានធ្លាក់ផុស ក្បាលមិត្តវិន្ទុកដល់ហើយ ៖ ក៏វិលត្រឡប់បាក់បោះបំ ក្បាលមិត្តវិន្ទុកនោះ ដូចគេបុក គេកិនដោយត្បាល់ ដែក អង្រែដែក ឈើបំផ្លែកមហិមាក្រៃពេក ទើប ដឹងខ្លួនថាជាកងចក្រ ហើយស្រែកប្រាប់ទៅសត្វ នរកនោះវិញថា នែអ្នក ចូរអ្នកទទួលយកកងចក្រ របស់អ្នកទៅវិញទៅ ខ្ញុំលែងចង់បានហើយ ឯសត្វ នរកនោះ ក៏ស្ងាត់បាត់ទៅក្នុងពេលនោះ បំណែក ខាងមិត្តវិន្ទុក តាំងអំពីបានទ្រទ្រង់នូវកងចក្រនោះ ផលាណាហើយ ក៏បានសេចក្តីទុក្ខធំ សោយទុក្ខ ផទនារកទីស្រោកស្រោន្តគ្មាន ឯសេចក្តីទុក្ខទាំង នេះ ព្រោះតែផលបាបដែលខ្លួនប្រទូស្ត ៖ តប់ប្រហារលោកជាមាតា ឥតញញើតនោះឯង

មិត្តវិន្ទកបានសោយទុក្ខនៅក្នុងទីនោះជាយូរអង្វែង លុះអស់ផលបាបនោះវេលាណា ក៏បានរួចចេញទៅតាមយថាកម្មហោង ។

ក្នុងអដ្ឋកថាសរភង្គជាតក មានសំដែងអំពីព្រះមហាមោគ្គល្លានត្ថេរ កាលជាតិអំពីមុនយូរមកហើយ ថាជាអ្នកចេះគោរពប្រតិបត្តិមាតាបិតាដែរ តែភ្លាត់ដោយជឿពាក្យប្រពន្ធ ហើយត្រឡប់ទៅជាប្រទូស្តអ្នកមានគុណវិញ ក៏បានដល់នូវសេចក្តីទុក្ខជាទម្ងន់ ក្នុងពេលដែលស្លាប់ទៅនោះ ។

ឯរឿងនោះ ដូចមានសេចក្តីខាងក្រោយនេះ :

បានដឹងដំណឹងប្រាកដមកថា ក្នុងកាលដ៏កន្លងទៅយូរហើយ មានបុរសម្នាក់ នៅទៀបក្រុងពារាណសី បុរសនោះ ជឿស្តាប់តែពាក្យប្រពន្ធ

ខ្លួន ហើយកើតមានចិត្តសម្លាប់មាតាបិតារបស់ខ្លួន
វិញ តាំងព្យាយាមរកឧបាយនឹងសម្លាប់មាតាបិតា
នោះ មានកាលមួយថ្ងៃ បុរសនោះ ឲ្យម្ដាយ
អាពុកនោះឡើងជិះរទេះ ហើយបរចេញទៅក្នុង
ព្រៃ ដើម្បីសម្លាប់ចោល លុះដល់ពាក់កណ្ដាលព្រៃ
ហើយ ក៏ក្លែងនិយាយបញ្ឆោតអ្នកទាំងពីរនោះថា
នែអ្នកម្ដាយអ្នកអាពុក ក្នុងព្រៃនេះ តែងមានចោរ
ពួននៅចាំប្លន់ជាច្រើន ឯខ្លួនខ្ញុំនឹងចុះពីរទេះនេះ
ទៅរាំងមើល និយាយប៉ុណ្ណោះហើយ ក៏ហុចខ្សែ
គោនោះទៅដៃបិតា ហើយចុះដើរទៅ លុះចុះដើរ
ទៅបន្តិចហើយ ក៏ក្លែងស្រែកសម្រែកយ៉ាងខ្លាំង ធ្វើ
អាការបីដូចជាសំឡេងចោរ ស្ទុះមកទះតប់នូវមាតា
នឹងបិតានោះយ៉ាងខ្លាំង បំរុងនឹងឲ្យស្លាប់ក្នុងទីនោះ

ឯផនទាំងពីរ ជាមាតាបិតានោះ ក៏ហេតុតែជាមនុស្សចាស់ជរា មានភ្នែកងងឹតអន្ធការ នឹងមើលរូបកូនឯងនោះក៏ពុំស្គាល់ ទឹកស្មានថាជាចោរប្រាកដឥតសង្ស័យ ហើយទើបស្រែកទ្រហោយំប្រាប់ទៅកូននោះថា អីកូនសំឡាញ់ម្តាយអើយចោរមកឯណោះហើយ កំពុងតែវាយម្តាយនឹងអាពុកអ្នក ចូរកូនប្រុសម្តាយអ្នករត់ចៀសចេញឲ្យឆ្ងាយទៅ ។

បំណែកខាងកូននោះ កំពុងតែវាយមាតាបិតារបស់ខ្លួន លុះឮសំដីអ្នកទាំងពីរនោះ ស្រែកប៉ូរទ្រហោយំ ប្រាប់មកខ្លួនជាកូនថា ឲ្យរត់ចេញឲ្យឆ្ងាយទៅ ត្រង់ជីវិតខ្លួនអ្នកម្តាយអ្នកអាពុកលោកពុំគិតឡើយ លុះឮប្រាកដដូចប្លោះហើយ ក៏កើត

មានចិត្តអាណិតមេត្តាដល់មាតាបិតានោះក្រៃពេក វិញ ទើបឈប់វាយ ហើយគេចចេញទៅក្បែរខាង បន្តិច រួចត្រឡប់ដើរចូលមក ក៏និយាយលួងលោម អ្នកទាំងពីរនោះថា នែមាតាបិតា ឯចោរនោះរត់ បាត់អស់ទៅហើយ ចូរអ្នកកុំមានសេចក្ដីភិតភ័យ ឡើយ ហើយលើកមាតាបិតាឲ្យឡើងជិះរទេះ រួច បរត្រឡប់(១)មកផ្ទះវិញ ។

ឯបុរសជាកូននោះ ក៏ចិញ្ចឹមមាតាបិតាដរាបទៅ លុះដល់បុរសនោះស្លាប់ទៅវេលាណា ក៏ធ្លាក់ចុះ ទៅសោយទុក្ខក្នុងនរកអស់កាលដ៏យូរ ហើយ

---

១ ក្នុងគម្ពីរព្រះធម្មបទភាគ ា មានសេចក្ដីសំដែងថា បុរសដែលជាកូននោះ វាយមាតាបិតាទាំងពីរនោះដរាបដល់ស្លាប់ ហើយលើកបោលទៅលើគុម្ពោតឈើក្នុងព្រៃនោះឯង ។ ឯក្នុងគម្ពីរមង្គលត្ថទីបនីនេះថា គ្រាន់តែវាយបន្តិចហើយកើតចិតអាណិត ក៏ឈប់វាយទៅ លើកមាតាបិតានោះឲ្យជិះរទេះ ហើយបរមកផ្ទះវិញ ។

ត្រឡប់ទៀងមកកើតជាមនុស្ស ៗ នោះតែងស្លាប់នឹងចោរវាយនោះ ប្រមាណ ១០០ ជាតិ ព្រោះតែផលបាបដែលខ្លួនបៀតបៀនមាតាបិតានោះ លុះដល់ជាតិជាបំផុត ក៏បានមកកើតជាព្រះមហាមោគ្គល្លានថេរ ជាអគ្គសាវកទីពីរ ដោយអំណាចផលបុណ្យដែលលោកបានកសាងផ្សេង ៗ ក្នុងលំដាប់នៃភពនោះ ៗ តែគង់ព្រះមហាមោគ្គល្លានថេរ ត្រូវទទួលនូវវេរាអំពីចោរសម្លាប់ខ្លួននោះទៀតមិនខាន ព្រោះតែផលកម្មចាស់នោះពុំទាន់អស់នៅឡើយ ។

ម្យ៉ាងទៀត ឯការបំរើរក្សានូវមាតាបិតានោះ បើប្រសិនជាកូនប្រុសស្រីឯណា បានគោរពប្រតិបត្តិត្រូវល្អហើយ គង់នឹងនាំមកនូវសេចក្ដីសុខគ្រប់

ប្រការ នឹងសេចក្តីចំរើនគ្រប់យ៉ាង ដល់កូនទាំងនោះ ក្នុងលោកនេះ នឹងលោកខាងមុខ មិនលែងឡើយ ដូចមានពុទ្ធភាសិតទ្រង់សំដែងទុកមក ក្នុងព្រហ្មសូត្រ នឹងសោណនន្ទជាតកជាបទគាថាថាដូច្នេះ:

តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា

ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ ។

សេចក្តីថា (អ្នកឯណា) បានប្រតិបត្តិបំរើនូវបិតាមាតារបស់ខ្លួនហើយ អ្នកប្រាជ្ញទាំងឡាយតែងសរសើរនូវអ្នកនោះ ក្នុងលោកនេះថា អ្នកនេះជាមនុស្សមានចិត្តកតញ្ញូ បេះប្រតិបត្តិនូវអ្នកដ៏មានគុណបំពោះលើខ្លួន ឯការប្រតិបត្តិយ៉ាងនេះហើយ ដែលជាផ្លូវ ឬ ជាជណ្តើរ សម្រាប់អ្នកនោះ

នឹងឡើងទៅកើតក្នុងទេវស្ថាន គឺស្ថានសួគ៌នោះ មិនខាន ដល់វេលានឹងទៅកាន់លោកខាងមុខទៀត ក៏អ្នកនោះឯង គង់នឹងបានប្រទះនូវលាភយ៉ាងធំ គឺ សេចក្ដីរីករាយសប្បាយចិត្ត ដោយទិព្វសម្បត្តិ ទាំងឡាយម្ដងទៀត ។.

ក៏ធម្មតាអ្នកឧបដ្ឋាកនូវមាតាបិតានេះ អង្គព្រះ សម្មាសម្ពុទ្ធ តែងសរសើរជាពន្លឹកក្រៃពេក ជា អនេកបរិយាយ សឹងមានរឿងនិទានទុកមកជា បែបយ៉ាងខ្លះ ដូចខាងក្រោយនេះ :

បានដឹងដំណឹងប្រាកដមកថា ក្នុងគ្រាមួយនោះ មានកូនសេដ្ឋីម្នាក់ នៅទៀបក្រុងសាវត្ថី កុមារ នោះបានចូលទៅស្ដាប់ធម៌ទេសនាព្រះបរមសាស្ដា ក៏មានចិត្តជ្រះថ្លា ហើយបានចូលទៅសូមបព្វជ្ជា

ឧបសម្បទាជាភិក្ខុ ក្នុងព្រះពុទ្ធសាសនា បានរៀនសូត្រធម៌វិន័យ នៅក្នុងសំណាក់ព្រះឧបជ្ឈាយ៍បាន ៥ វស្សា ហើយបានទាំងសូមរៀនព្រះកម្មដ្ឋានអំពីព្រះឧបជ្ឈាយ៍ រួចលាព្រះឧបជ្ឈាយ៍ចេញអំពីវត្តជេតពននោះ ទៅកាន់ស្រុកបច្ចន្តគ្រាម ហើយក៏អាស្រ័យនៅៗទីនោះ ។ បំណែកខាងសេដ្ឋីប្តីនឹងប្រពន្ធ ជាមាតាបិតានៃភិក្ខុនោះ តាំងអំពីកូនទៅបួសវេលាណា ឯទ្រព្យសម្បត្តិទាំងពួង ក៏ចេះតែខូចខាតបាត់បង់ទៅជាលំដាប់ ៗ រហូតដល់ធ្លាក់ខ្លួនទៅជាមនុស្សកំសត់ កំព្រាអនាថា រកអាហារចិញ្ចឹមជីវិតពុំបាន ក៏កាន់ឆ្នូរអម្បែងដើរសូមទានគេស៊ី តាមបវេណីនៃអ្នកទាល់ក្រនោះឯង ឯទីកន្លែងដែលនឹងដេកនៅនោះទៀត ក៏ជាទីស្មោក

គ្រោកអាក្រក់ពេក នឹងប្រៀបពុំបាន គឺថាជនទាំងពីរនេះ តែងដេកនៅតែជិតជើងរបង ឬ ទៀបជញ្ជាំងផ្ទះនៃអ្នកដទៃ គួរឲ្យកើតសង្វេគពេកណាស់ ៗ

លុះបំណោរមកខាងក្រោយ ដំណឹងនោះក៏ដឹងឮប្រាកដទៅដល់លោកជាកូន ដែលទៅនៅរៀនព្រះកម្មដ្ឋានឯស្រុកក្រៅនោះ ទើបលោកនោះមានបិត្តគិតអាណិតដល់មាតាបិតា ដែលជាអ្នកធ្លាប់មាន ធាប់សុខមកយូរហើយ ៗ មកធ្លាក់ខ្លួនទៅជាមនុស្សកំព្រាអនាថាវិញ ហើយលោកនោះក៏គិតក្នុងចិត្តថា ឪអាត្មាអញ សព្វថ្ងៃនេះ កំពុងតែទំនុសប្រហ័ព្យាយាមបំរើនមេត្តាភាវនា ដើម្បីនឹងឡូសម្រេចមគ្គផលដល់ខ្លួន អស់ប្រមាណ ១២ ឆ្នាំ

មកហើយ ឥឡូវមគ្គផលដែលជាគុណវិសេសនោះ
ក៏មិនបានសម្រេច ចំណែកខាងអ្នកដ៏មានគុណទាំង
ពីរនោះទៀត ដូចនេះ គប្បីបណ្តាក់ខ្លួនទៅជាអ្នកកំព្រា
អនាថា រកទីពឹងគ្មាន ខ្ញុំអញអើយ ជាអ្នកអភ័ព្វ
ពេក គួរឲ្យកើតសង្វេគអណោចអធម្មអ្វីម្ល៉េះទេ
បើយ៉ាងនឹងហើយ អាត្មានឹងទ្រាំនៅជាអ្នកបួសឯ
ណាក៏បាន គួរតែសឹកចេញទៅធ្វើការ បំរើលោក
អ្នកដ៏មានគុណទាំងនោះ ហើយសឹមធ្វើទានរក្សា
សីលទៅចុះ ក៏គង់នឹងបានសម្បត្តិសួគ៌ សម្បត្តិ
សុខដែរ លុះគិតឃើញដូច្នេះហើយ ក៏ដើរចេញ
អំពីស្រុកបច្ចន្តប្រទេសនោះមក កាត់ដម្រង់ទៅក្នុង
ក្រុងសាវត្ថី លុះដល់ហើយ ក៏គិតថា អាត្មាអញក្នុង
ថ្ងៃនេះ គួរនឹងចូលទៅកាន់វត្តព្រះជេតពន ដើម្បី

បានថ្វាយបង្គំគាល់ព្រះបរមសាស្តា ហើយនឹង
ស្តាប់ធម៌ទេសនាផង លុះដល់ព្រឹកឡើង សឹម
ទៅជួបនឹងញោមទាំងពីរនោះបុះ ។

ទិវសំ ចេន សត្ថា បច្ចូសកាលេ លោកំ
លោកេន្តោ តស្ស បឋមមគ្គោបនិស្សយំ
ស្វា ។ល។

ដប៉ើនោះ អង្គសម្តេចព្រះបរមសាស្តា ស្តេច
ព្រះដ៏រិះ គយគន់គិតមើលនូវឧបនិស្ស័យ
នៃសត្វលោក ក្នុងវេលាទៀបនឹងអរុណរះ
ក៏ទ្រង់ឃើញច្បាស់ថា ភិក្ខុនោះនឹងបានលុះ
តាបត្តិផល ជាប្រាកដមិនខាន លុះដល់
ដលភិក្ខុនោះចូលមកគាល់ ទ្រង់ក៏លើកធម៌
មកសំដែង រៀបរាប់ពណ៌នានូវគុណូបការ

របស់មាតាបិតា ក្នុងមាតាបិតុបោសកសូត្រ បំពោះឲ្យភិក្ខុនោះស្តាប់ ឯភិក្ខុនោះ លុះបានស្តាប់ធម៌ទេសនា ក្នុងមាតាបិតុបោសកសូត្រនោះហើយ ក៏គិតពិចារណាថា អាត្មាអញ កាលដែលចេញមកពីព្រៃនោះ បំរុងថានឹងសឹកចេញទៅធ្វើភេទជាគ្រហស្ថ ហើយនឹងបំរើមាតាបិតារបស់ខ្លួន ឥឡូវនេះ ព្រះសាស្តាស្តេចទ្រង់ទេសនាថា អ្នកបួសគួរនឹងធ្វើកិច្ចបំរើនូវមាតាបិតាបានឥតទាស់ទេ ឯអាត្មាអញ បើប្រសិនជាមិនបានបួលមកគាល់ស្តាប់ធម៌ទេសនានេះ ក៏សមនឹងវិនាសបាកផ្នួសនេះមិនខានឡើយ តែឥឡូវនេះ ខ្លួនអញក៏ជាអ្នកបួសស្រាប់ហើយ គួរតែខំសង្វាតបំរើរក្សានូវលោកអ្នកដ៏មានគុណទាំងពីរនោះ ឲ្យបានស្រួលតាមប្រាថ្នា ។ លុះថ្ងៃព្រឹក

ទៀង ភិក្ខុអង្គនោះ ក៏កាន់យកនូវបាត្រ ហើយ ចូលទៅទទួលយកនូវសលាកយាគុ និងសលាកភត្ត រួចចូលទៅកាន់ស្រុក ដើម្បីនឹងទទួលយកបបរនឹងភោជន លុះបានភោជនាហារទាំងនោះហើយ ក៏យកទៅជូនដល់ញោមទាំងពីរនោះ ឯញោមទាំងពីរ កាលបើបានឃើញលោកកូននោះកាន់យកទាំងអាហារ ម្ហូប បំណីមកផង អ្នកក៏មានចិត្តសោមនស្ស ត្រេកអរជាទីបំផុត រកអ្វីនឹងប្រៀបពុំបាន ឯភិក្ខុអង្គនោះ លុះបានជូនវត្ថុទាំងពួងនោះដល់មាតាបិតាហើយ ក៏ធ្វើភត្តកិច្ចឆាន់ដោយខ្លួនឯងជាខាងក្រោយ រួចហើយក៏ចាត់ចែងធ្វើនូវទីលំនៅ សម្រាប់ឲ្យមាតាបិតានៅដោយស្រួល ។

ឯភិក្ខុនោះ ចាប់ដើមតាំងអំពីថ្ងៃនោះមក លោក

ក៏ប្រឹងតែខំសង្វាតស្វះស្វែងរកភោជនាហារ ជូនមាតាបិតានោះ បរិភោគរាល់ៗថ្ងៃជានិច្ច កាលណាញោមលោកនោះបរិភោគហើយ ទើបលោកភិក្ខុនោះ ចេញទៅស្វែងរកបិណ្ឌបាតឆាន់ខ្លួនឯងជាខាងក្រោយ កាលបើរកបិណ្ឌបាតបានមកក៏ឆាន់ទៅ បើរកពុំបានទេ ក៏អត់ស្ងៀមក្នុងថ្ងៃនោះ ឯថ្ងៃដែលនឹងបិណ្ឌបាតបានមកឆាន់នោះ តិចពេកណាស់ ច្រើនតែថ្ងៃដែលបិណ្ឌបាតមិនបានៗ

ម្យ៉ាងទៀត ឯភិក្ខុអង្គនោះ លោកមិនមែនគ្រាន់តែចិញ្ចឹមមាតាបិតានោះ ដោយអាហារបិណ្ឌបាតប៉ុណ្ណោះទេ គឺលោកជូនទាំងសំពត់សម្រាប់ស្លៀកនិងដណ្ដប់ផង សំពត់ឯណាដែលមាតាបិតាស្លៀកដណ្ដប់ចាស់ហើយ លោកក៏យកសំពត់នោះ មក

បោកគក់ ប៉ះ ជ្រលក់ ធ្វើជាស្បង់ចីពរប្រើប្រាស់ដោយខ្លួនឯង ។ ឯភិក្ខុនោះ លោកខំប្រព្រឹត្តធ្វើការចិញ្ចឹមមាតាបិតានោះ ក៏ជាទីបំផុតពេកណាស់ រហូតដល់ខ្លួននោះ ស្គាំងស្គមអាប់អន់ទាំងសម្បុរនោះផង ទើបភិក្ខុទាំងឡាយ បានឃើញហេតុដូច្នោះហើយ ក៏សួរភិក្ខុនោះ ហើយក៏បានដឹងដំណឹងប្រាកដថា ភិក្ខុនោះ ដែលមានខ្លួនស្គាំងស្គមយ៉ាងនេះ ព្រោះតែបំរើមាតាបិតានោះឯង ទើបភិក្ខុទាំងឡាយ ក៏លើកទោសនិន្ទាជាច្រើន ហើយយកសេចក្តីនុ៎ះក្រាបបង្គំទូលដល់ព្រះបរមសាស្តា ៗ ស្តេចបានជ្រាបនូវហេតុនោះជាមុនហើយ តែទ្រង់មានប្រាថ្នាដើម្បីនឹងឲ្យសព្វសាធុការ ដល់មាតុបោសកភិក្ខុនោះ ហើយព្រះអង្គនឹងប្រកាសនូវ

មុខចំពោះព្រះអង្គ ឲ្យភិក្ខុទាំងឡាយស្តាប់ផង លុះ
ភិក្ខុនោះបួសមកដល់ហើយ ទើបព្រះអង្គទ្រង់សួរ
ថា យេ តេ ត្វំ ភិក្ខុ បោសេសិ កិន្តេ តុយ្ហំ ហោន្តិ
នែភិក្ខុ អ្នកឯងដែលចិញ្ចឹមនូវជនចាស់ ៗ
ទាំងឡាយនេះ តើជនទាំងនោះ ត្រូវជាអ្វីចម្ដេចនឹង
អ្នក ។ មាតាបិតរោ មេ ភន្តេ បពិត្រព្រះដ៏មាន
ព្រះភាគដ៏ចំរើន ឯជនទាំងពីរដែលចាស់ជរានោះ
មិនមែនជាអ្នកដទៃទេ គឺមាតាបិតារបស់ខ្ញុំព្រះ
អង្គ ។ សាធុ សាធុ ឯអង្គសម្ដេចព្រះអនាវរណ
ញ្ញាណទ្រង់ឲ្យនូវសាធុការថា សាធុ សាធុ ជាគំរប់
៣ ដង ដល់ភិក្ខុនោះ ហើយទើបទ្រង់សរសើរ
ភិក្ខុនោះថា នែភិក្ខុ អ្នកឯងជាអ្នកបានស្ថិតនៅត្រង់
ផ្លូវដែលតថាគតធ្លាប់ដើរមកហើយ ឯតថាគត

បានប្រព្រឹត្តនូវបុព្វចរិតយ៉ាងនេះ ជាច្រើនជាតិ
គឺតថាគត បានថ្នាក់ថ្នមថែរក្សានូវមាតាបិតាទាំង
ពីរនោះ ឥតមានធ្វេសប្រហែស ហើយទ្រង់
សំដែងនូវសុវណ្ណសាមជាតក ទុកក្នុងមហានិបាត
ថា ភិក្ខវេ មាតាបិតុបោសកំ នាម បណ្ឌិតានំ
វំសោ ម្នាលភិក្ខុទាំងឡាយ ឯអ្នកដែលបានចិញ្ចឹម
នូវមាតាបិតានោះឈ្មោះថា ជាវង្សនៃអ្នកប្រាជ្ញ
ទាំងឡាយអំពីមុនមក ហើយទើបទ្រង់ប្រកាសនូវ
សច្ចធម៌ទាំងឡាយ ដរាបដល់ចប់ៗឯមាតុបោសក
ភិក្ខុនោះ ក៏បានលុះដល់សោតាបត្តិផល ក្នុងវេលា
ដែលចប់សច្ចធម៌នោះឯងហោង ។

មានភិក្ខុ ១ រូបទៀត ជាអ្នកមានចិត្តប្រកប
ដោយកតញ្ញូកតវេទីធម៌ បានគោរពប្រតិបត្តិបំរើនូវ

[illegible]

មាតាបិតាទាំងពីរនោះ [illegible] ឲ្យជាមាតុបោសកភិក្ខុនោះដែរ លុះបានជ្រាបដល់សម្ដេចព្រះទសពលញាណ ទ្រង់ត្រាស់ប្រទានពរដល់ភិក្ខុអង្គនោះ ហើយទ្រង់សំដែងនូវសុត្តនជាតក ក្នុងសត្តកនិបាត នឹងទ្រង់ប្រកាសនូវសច្ចធម៌ លុះចប់ធម៌ពិតនោះទៅ ភិក្ខុនោះ ក៏បានដំកល់នៅក្នុងសោតាបត្តិផល ។

ព្រះបរមសាស្ដា ស្ដេចទ្រង់ប្រទានពរសព្ទសាធុការដល់ភិក្ខុ ១ រូបទៀត ដែលជាអ្នកបំរើមាតាបិតាដែរថា នែភិក្ខុ អ្នកឯងដែលបានចិញ្ចឹមនូវអ្នកដ៏មានគុណនោះ ត្រូវល្អពេកណាស់ ជាបវេណីនៃអ្នកប្រាជ្ញទាំងឡាយអំពីបុរាណនាយ ឯអ្នកប្រាជ្ញទាំងឡាយអំពីមុនមក កុំបីឡើយ លោក

បានកើតមកជាមនុស្សជាតិ សូម្បីលោកកើតជាសត្វតិរច្ឆានក្តី ក៏គង់មានសេចក្តីគោរពប្រតិបត្តិជួយឲ្យនូវជីវិតដល់មាតាបិតារបស់លោកដែរ រួចទ្រង់សំដែងនូវនន្ទិយមិគជាតក ក្នុងឆក្កនិបាត ឲ្យភិក្ខុនោះស្តាប់ ដរាបដល់ចប់ ។ តពីនោះមក ព្រះសម្ពុទ្ធទ្រង់ឲ្យនូវពរសំពត្សាធុការដល់ភិក្ខុ ១ រូបទៀត ដែលជាអ្នកធ្វើនូវឧបដ្ឋានកិច្ច ដល់មាតាបិតានោះដែរ ហើយទ្រង់សំដែងនូវគិជ្ឈជាតក ក្នុងសត្តកនិបាត ឲ្យភិក្ខុនោះស្តាប់ ដរាបដល់ចប់ ។ តពីនោះមក ព្រះសព្វញ្ញូបរមគ្រូ ព្រះអង្គសរសើរនូវភិក្ខុ ១ រូបទៀត ដែលជាអ្នកបំរើនូវមាតាបិតាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាកុំលើកទោសនិន្ទានូវភិក្ខុរូបនេះឡើយ [illegible] សូម្បីអ្នកប្រាជ្ញទាំងឡាយ [illegible]

[illegible]

ក៏លោកតែងផ្ដើមបន្ទូលបញ្ជាក់គុណ ... ដល់ជន ទាំងឡាយដែលមិនមែនជាញាតិក៏មាន ព្រោះតែ ជនទាំងនោះ គេមានគុណចំពោះអង្គលោក ឯការ បំរើនូវមាតាបិតានេះ ជាកិច្ចយ៉ាងឧត្ដមរបស់ភិក្ខុ រូបនេះ ហើយមិនមែនខុសទេ រួចទ្រង់សំដែងនូវ គិជ្ឈជាតក ក្នុងទុក្កនិបាត ឲ្យភិក្ខុនោះស្ដាប់ ដរាប ដល់ចប់ ។ តពីនោះមក ទ្រង់សរសើរនូវភិក្ខុ ១ រូប ទៀត ជាអ្នកដឹងគុណមាតាបិតានោះដែរថា នែ ភិក្ខុ អ្នកប្រាជ្ញទាំងឡាយអំពីដើម លោកមានភ្ជាត់ ជាតិទៅកើតជាសត្វស្លាប សត្វតិរច្ឆាន លោកតែង ផ្ដេកនូវមាតាបិតារបស់លោក ដែលចាស់ជរានោះ ឲ្យដេកនៅក្នុងសំបុក ហើយខ្លួនលោកខំស្វះស្វែង រកអាហារ ពាំនាំមកដោយបំពុះ គឺមាត់ យកមក

បិញ្ចឹមមាតាបិតា ដែលចាស់ជរានោះឯង ហើយទ្រង់សំដែងនូវកេទារជាតក ក្នុងបកិណ្ណកនិបាតតទៅ ។

លំដាប់ពីនោះមក ទ្រង់ឲ្យនូវសព្ទសាធុការដល់ភិក្ខុ ១ រូបទៀត ហើយទ្រង់ប្រកាសប្រាប់ភិក្ខុទាំងឡាយថា នែភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំមើលងាយភិក្ខុរូបនេះ ដែលជាអ្នកធ្វើកិច្ចឧបត្ថម្ភនូវមាតាបិតានោះឡើយ អ្នកប្រាជ្ញទាំងឡាយអំពីដើម ទោះបីលោកកើតជាដំរី ជាសត្វតិរច្ឆាន ក៏លោករាប់អានស្រឡាញ់មាតារបស់លោកជាទីបំផុត សេចក្ដីថា ក្នុងសម័យមួយ ដំរីនោះ ស្ដេចចាប់បំបែកពីមេទៅប្រមាណជា ៧ ថ្ងៃ ក៏អត់នូវអាហារចំណីមិនព្រមបរិភោគសោះ ដរាបដល់ស្គាំងស្គម

ពេកណាស់ ព្រោះតែបែកពីមេរបស់លោក ដោយ
ហោះទៅ សូម្បីតែចំណីដែលមានដីទៀ ដែល
ស្ដេចប្រទានឲ្យ ក៏មិនព្រមបរិភោគ ព្រោះដីរនោះ
បានតាំងគំនិតគិតថា បើបានជួបនឹងមាតាវេលា
ណា ទើបបរិភោគនូវអាហារក្នុងពេលនោះ បើ
មិនជួបទេ ក៏មិនព្រមស៊ីអាហារនោះ ដរាបដល់
ស្លាប់ ។ ព្រះបរមគ្រូ ទ្រង់សំដែងនូវមាតុបោសក-
ជាតក ក្នុងឯកាទសកនិបាត ដរាបដល់ចប់
រួចទ្រង់ប្រកាសនូវសច្ចធម៌ដល់ភិក្ខុទាំងឡាយ លុះ
ចប់ធម៌ទេសនាទាំងនោះវេលាណាហើយ ភិក្ខុ
ទាំង ៥ រូបនោះ ក៏បានសិតនៅក្នុងសោតាបត្តិ
ផល ក្នុងកាលនោះ ។

ព្រោះហេតុនោះហើយ បានជាព្រះសាស្ដាចារ្យ

ទ្រង់សរសើរនូវបុគ្គល ដែលជាអ្នកគោរពប្រតិបត្តិ បំរើមាតាបិតានោះថា នឹងបានសម្រេចនូវប្រយោជន៍របស់ខ្លួនជាប្រាកដមិនខាន ដូចជាភិក្ខុទាំង ៧ រូប[១] នោះឯង ។

ម្យ៉ាងទៀត ធម្មតាអ្នកដែលចិញ្ចឹមរក្សានូវអ្នកដ៏មានគុណទាំងនោះ ទោះបីមានគ្រោះថ្នាក់យ៉ាងធំ មានត្រូវព្រួញដែលប្រឡាក់ដោយថ្នាំពិសយ៉ាងខ្លាំងជាដើមក្តី ក៏គង់របូតរួចចេញអំពីសេចក្តីស្លាប់នោះបាន ដូចព្រះសុវណ្ណសាមបរមពោធិសត្វនោះ ពុំនោះសោត ដូចព្រះសុត្តនពោធិសត្វដែលបានរួចចេញអំពីកណ្តាប់ដៃយក្ស និងនន្ទិយ

១ ភិក្ខុ ២ រូប ដែលសម្រេចសោតាបត្តិផលខាងដើមនិង ៥ រូបខាងចុង ត្រូវជា ៧ រូប ។

ម្រឹគ ដែលឃ្លានរួចចេញពីទីដែលគេឃុំរក្សា នឹងស្ដេចត្មាត ស្ដេចសេក នឹងស្ដេចដំរី ដែលបានរួចចេញពីអន្ទាក់មំណោង ដែលជនគេចងរក្សាទុក នោះឯង ។

ឯការដែលឧបដ្ឋាកនូវមាតាបិតានេះ មានគុណានិសង្សយ៉ាងច្រើន ដូចសេចក្ដីដែលសំដែងមកហើយនេះ ។

សំដែងមក ក្នុងមាតាបិតុឧបដ្ឋានកថានេះ មិនទាន់ចប់ទេ តែដល់សេចក្ដីដែលល្មមនឹងបញ្ចប់ប៉ុណ្ណោះហើយដោយសង្ខេប ។

# បញ្ជីសៀវភៅ

## ដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយ

## ភាសាខ្មែរនិងបាលី

| | | |
|---|---|---|
| អំពីព្រះសាសនខ្មែរនៅអង្គរ (ឥតរ) . . . | ១សៀវភៅថ្លៃ | ១៣,០០ |
| សុរ្យយាត្រាឡើងស័ក . . . . . . | | ៣,០០ |
| បក្ខគណនាវិធី និងបក្ខសម្រេច . . . | | ៣,០០ |
| រើបង្ការភេទ . . . . . . . . | | ១,០០ |
| ជយប្ប៉ូនរី ៣ . . . . . . . . . | | ៥,០០ |
| បទានុក្រមកមគ្គើ . . . . . . . | | ៦,០០ |
| មគ្គុទ្ទេសជនេរ ភាគទី ១ . . . . . | | ៨,០០ |
| ភាគទី ២ . . . . . | | ២,០០ |
| ទស្សនាវដ្តីឆ្នាំ ១៩៤៩ មួយឆ្នាំ . . . | ១២ | ៩៦,០០ |
| " ១៩៥០ . . . . . | | ១៤៥,០០ |
| " ១៩៥១ . . . . . | | ១៤៥,០០ |
| " ១៩៥២ . . . . . | | ១៨៣,០០ |
| " ១៩៥៣ . . . . . | | ១៩២,០០ |
| " ១៩៥៤ . . . . . | | ២០០,០០ |
| " ១៩៥៥ . . . . . | – | ២១០,០០ |

| | | | | |
|---|---|---|---|---|
| ទស្សនាវដ្តីឆ្នាំ ១៩៥៦ ទូទាំងឆ្នាំ | | ..១២ សៀវភៅថ្លៃ | | ២៨០,០០ |
| " | ១៩៥៧ | " ... | – | ២៣០,០០ |
| ឯកសារហសាក្រើភាគទី | ១ | ... | ១ – | ៥,០០ |
| " | ២ | ... | – | ៤,០០ |
| " | ៣ | ... | – | ៤,០០ |
| " | ៤ | ... | – | ៤,០០ |
| " | ៥ | ... | – | ៤,៥០ |
| " | ៦ | ... | – | ៣,០០ |
| " | ៧ | ... | – | ៥ ០០ |
| " | ៨ | ... | – | ៥·០០ |
| " | ៩ | ... | – | ៤·០០ |
| " | ១០ | ... | – | ២·០០ |
| " | ១១ | ... | – | ២·៥០ |
| " | ១២ | ... | – | ២,០០ |
| " | ១៣ | ... | – | ៥,០០ |
| " | ១៤ | ... | – | ៧,០០ |
| " | ១៥ | ... | – | ១០,០០ |
| " | ១៦ | ... | – | ៦,៥០ |
| " | ១៧ | ... | – | ៥,៥០ |

| | | | |
|---|---|---|---|
| ឯកសហស្រកត្រីកាន ទី | ១៨ . . . | ១ សៀវភៅ | ថ្លៃ៥.០០ |
| " | ១៩ . . . | – | ៧.៥០ |
| " | ២០ . . . | – | ៨.០០ |
| " | ២១ . . . | – | ៨.០០ |
| " | ២២ . . . | – | ៨.០០ |
| " | ២៣ . . . | – | ៨.០០ |
| " | ២៤ . . . | – | ៨.០០ |
| " | ២៥ . . . | – | ៦.០០ |
| " | ២៦ . . . | – | ៧.០០ |
| " | ២៧ . . . | – | ៧.០០ |
| " | ២៨ . . . | – | ៨.០០ |
| " | ៣០ . . . | – | ៧.០០ |
| " | ៣១ . . . | – | ៨.០០ |
| " | ៣២ . . . | – | ៨.០០ |
| " | ៣៣ . . . | – | ៨.០០ |
| " | ៣៤ . . . | – | ៨.០០ |
| " | ៣០ . . | – | ៨.០០ |

| | | |
|---|---|---|
| ឯកសហសាត្រីកាយ ទី ៣៦ . . . | ១ សៀវភៅថ្លៃ | ៨,០០ |
| " ៣៧ . . . | – | ៨,០០ |
| " ៣៨ . . . | – | ៨,០០ |
| វិសុទ្ធិមគ្គ ភាគទី ១ . . . . . . | – | ៥១,០០ |
| " ២ . . . . . . | – | ៥០,០០ |
| " ៣ . . . . . . | – | ៥០,០០ |
| វេយ្យាករណ៍សំស្ក្រឹត . . . . . . | – | ២៨,០០ |
| ព្រះបាទអសោក . . . . . . . | – | ១៦,០០ |
| គន្ធីអាស៊ីទ្វីប . . . . . . . . | – | ២៤,០០ |
| មហាវេស្សន្តរជាតក . . . . . . | – | ៤៣.០០ |
| សុភាសិតសូត្រ . . . . . . . . | – | ១,៥០ |
| ភាសាបាលីះបាលី . . . . . . . . | – | ៣៨'០០ |
| ជាតិមោក្ខសង្ខេប . . . . . . . | – | ៨' |
| ទសិទជាតិមោក្ខ . . . . . . . | – | ២១' |
| មរណានុស្សតិកម្មដ្ឋាន . . . . . | – | ៣'០០ |
| អត្ថានុសាសនី . . . . . . . . | – | ៦'៥០ |
| នានាជាតក . . . . . . . . . | – | ១២'០០ |
| សតិប្បដ្ឋានសូត្រនិងសំវេជនីយ . . . | – | ៨,៥០ |
| សម្ពុទ្ធមាលា . . . . . . . . | – | ៤១,០០ |

| | | |
|---|---|---|
| វចនានុក្រមខ្មែរ ភាគ ១ . . . . . | ១សៀវភៅថ្លៃ | ១០៥,០០ |
| " ភាគ ២ . . . . . | – | ១៣៦,០០ |
| អនត្តលក្ខណសូត្រ .. .. .. . | – | ២,០០ |
| វិជ្ជាចរណកថា និងគិរិមានន្ទសូត្រ . . | – | ៦,០០ |
| បញ្ញាខន្ធកសង្ខេប .. .. .. . | – | ៨,៥០ |
| សុភាសិតប្បកាសិនី .. .. .. . | – | ៣,០០ |
| កាលាមសូត្រនិងបរាភវសូត្រ . . . | – | ២,០០ |
| បាយាសិរាជញ្ញសូត្រ .. .. . . | – | ២,៥០ |
| គំរូក្បាច់ឆ្លាក់ខ្មែរ .. .. .. . . | – | ១២,០០ |
| អក្សរខ្មែរជាប់នឹងរូបសត្វ . . . . . | – | ០,០០ |
| សាមណេរវិន័យ .. .. .. . . | – | ៣,០០ |
| ពិធីទ្វាទសមាស ភាគ១ . . . . . | – | ១៥,០០ |
| " ភាគ២ . . . . . | – | ១៣,៥០ |
| អនុមោទនាវិធី .. .. .. . . | – | ៣,០០ |
| មាតាបិតុឧបដ្ឋានកថា .. .. . . | – | ៥,៥០ |
| សត្តបរិត្ត-ទ្វាទសបរិត្ត . . . . . | – | ១៣,០០ |
| គិហិបដិបត្តិពិស្តារ .. .. .. . | – | ១០,០០ |
| សីលនិទ្ទេស .. .. .. .. . | – | ១៦,០០ |
| ធម្មប្រទីប .. .. .. .. .. | – | ១០,០០ |

| | | |
|---|---|---|
| អវសានកិច្ច ................ | ១សៀវភៅថ្លៃ | ១០,៥០ |
| មិលិន្ទបញ្ហា ភាគទី១ .......... | | ២០,០០ |
| ភាគទី២. ......... | | ១៨,០០ |
| ដើមកំណើតអង្គរ ........... | | ១៣,០០ |
| អាឡវកសូត្រ ............. | | ៥,០០ |
| អរិយសច្ចកថា ............. | – | ១០,០០ |
| វិជ្ជាប្រាំបីប្រការ ........... | – | ១៤,៥០ |
| អភិធម្មត្ថសង្គហ ប្រែ ........ | – | ២៩,០០ |
| ប្រស្នាវិន័យបិដកសង្ខេប ....... | – | ២៩,០០ |
| រតនប្បភា ............. | – | ៧,០០ |
| ពុទ្ធមាមកវិធី ............. | – | ៨,០០ |
| បញ្ចអភិណ្ហប្បច្ចវេក្ខណៈ ....... | – | ៣,០០ |
| ទានកថា ............. | – | ៧,៥០ |
| សេលសូត្រ ............ | – | ៣,០០ |
| ទសបារមីកថា .......... | – | ៦,០០ |
| សៀវភៅយានជំនិះខ្មែរ ....... | – | ០,០០ |
| គម្ពីរវេជ្ជសារ ........... | – | ១០,៥០ |
| ជំហ៊ានបដិបត្តិសង្ខេប ......... | – | ០,០៩ |
| សុភាទោសកថា .......... | – | ៦,៥០ |

| | | |
|---|---|---|
| បញ្ញាសជាតក ប្រែ. . . , . . . . . . | ១ សៀវភៅថ្លៃ | ១៦,០០ |
| " បាលី. . . . . . . . . . . | – | ១៦'០០ |
| គតិលោក ភាគទី ១. . . . . . . . . . | – | ៤'០០ |
| " ២. . . . . . . . . . | – | ៤'០០ |
| " ៣. . . . . . . . . . | – | ៤,០០ |
| " ៤. . . . . . . . . . | – | ៤,០០ |
| " ៥. . . . . . . . . . | – | ៤,០០ |
| " ៦. . . . . . . . . . | – | ៤'០០ |
| " ៧. . . . . . . . . . | – | ៤'០០ |
| " ៨. . . . . . . . . . | – | ៤'០០ |
| " ៩. . . . . . . . . . | – | ៤'០០ |
| " ១០. . . . . . . . . . | – | ៤,០០ |
| ព្រហ្មចរិយកថា . . . . . . . . . . | – | ១៥'០០ |
| គោលសមថកម្មដ្ឋាន . . . . . . . . . | – | ៤'០០ |
| សីមាវិនិច្ឆ័យ . . . . . . . . . . . | – | ៣'០០ |
| មនោបុព្វកថា. . . . . . . . . . . . | – | ៣'០០ |
| រៀនអក្សរខ្មែរ . . . . . . . . . . . | – | ១'០០ |
| ប្រវត្តិព្រះមហាពោធិព្រឹក្ស . . . . . . . | – | ២'០០ |
| មិត្រល្អ . . . . . . . . . . . . | – | ១'០០ |

ទសធម្មសូត្រ .......... សៀវភៅថ្លៃ ០,០០

ទំនៀមការផ្សាល់ខ្លួន .......... ៣,០០

ទន្ទេសាប .......... ១,០០

ព្រះចង្កូមកែវ .......... ១,០០

ព្រះរាជពិធីរាជាភិសេក .......... ៥,០៦

អក្ខរទោសកថា .......... ១,៥០

អំពីព្រះពុទ្ធសាសនា .......... ៥១,០០

ញាណភកថា .......... ២,០០

និរណាស់ពុទ្ធចេតិយ .......... ០,០០

នានោបមាទិកថា .......... ១,៥០

១០០ ជាតិ .......... ០,០០

សារទេសនា .......... ២,០០

អនុត្តរិយសូត្រ .......... ១,០០

ពុទ្ធាភិទានសាសន៍ .......... ៤,០០

មហាបុរិសលក្ខណៈ .......... ១,០០

បុណ្ណោវាទសូត្រ .......... ១,០០

សីលាចារិកនគរវត្ត .......... ១០,០០

បីសាចស្នេហ .......... ០,០០

កុម្ភជាតក .......... ៣,០០

| | | |
|---|---|---|
| វេមាវេមសារណកថា . . . . . . | ១ សៀវភៅថ្លៃ | ០,០០ |
| ច្បួនភគីស័ក្ត . . . . . . . . | ” | ០,០០ |
| សំនៃងអំពីព្រះនិព្វាន . . . . . . | ” | ០,០០ |
| យកភិសធម៌ . . . . . . . | ” | ០,០០ |
| ពាក្យខ្មែរជាប់ទំនុបកាមកេ្ត . . . | ” | ០,០០ |
| វុត្តោទ័យ . . . . . . . . . | ” | ០,០០ |
| ឧករណវិសេសោ . . . . . . . | ” | ០,០០ |
| សង្គហេភទសូត្រ . . . . . . . | ” | ៦,០០ |
| កាមកេ្តពីខ្សែ ១ ដល់ខ្សែ១០ ពាក្យកាព្យ . . . . | ” | ៤,០០ |
| គីពិ៥ ដល់ ៨០ . . . . . . . . . | ” | ២,០០ |
| រឿងកាកី . . . . . . . . . . | ” | ៧,០០ |
| គិរីមានន្ទសូត្រ . . . . . . . . | ” | ៣,០០ |
| អភិនវកោសិក . . . . . . . . . | ” | ៣,០០ |
| ពាក្យកាព្យថ្លែងរឿងពុទ្ធប្បវត្តិ . . . . . | ” | ៣,០០ |
| ច្បាប់លើកខ្នាតកូនចៅចិន . . . . | ” | ០,០០ |
| ច្បាប់លើកតាស់គឿន . . . . . . | ” | ០,០០ |
| ច្បាប់ល្បើកថ្មី . . . . . . . . . | ” | ០,០០ |
| ភនគេតិ . . . . . . . . . . | ” | ០,០០ |
| ច្បាប់ស្រីគេតិ . . . . . . . . . | ” | ០,០០ |

| | | |
|---|---|---|
| ច្បាប់ក្រម | ១សៀវភៅថ្លៃ | ០'០០ |
| ថែបសកភិទ ឆ្នាំ ១៩៣១ | " | ០.៤៥ |
| " ១៩៣២ | " | ០.៤៥ |
| " ១៩៣៣ | " | ០.៤៥ |
| ច្បាប់កូនចៅ | " | ០,០០ |
| ច្បាប់ផ្សេងៗ ភាគ ១ | " | ៤.០០ |
| " ភាគ ២ | " | ០,០០ |
| ច្បាប់សុភាសិត | " | ៣'៥០ |
| សប្បុរិសធម៌ | " | ៩'៥០ |
| ច្បាប់ប្រដៅកូនប្រុសស្រីក្រមង្គ | " | ៣'០០ |
| សុភាសិតច្បាប់ស្រី | " | ៥'០០ |
| ចំរៀងគតិនិយម ភាគទី ១ | " | ៨'០០ |
| សេកសោមបណ្ឌិត | " | ៣'០០ |
| ច្បាប់កេរ្តិ៍កាល (ចាស់) | " | ០'០០ |
| ព្រះត្រៃលក្ខណ៍នឹងសំវេគកថា | " | ៤'០០ |
| ក្រុងសុភមិត្រ ភាគ ១ | " | ៥'០០ |
| " " ២ | " | ៤.០០ |
| " " ៣ | " | ៣.៥០ |
| សំវេគនិយធម៌ | " | ២.០០ |

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ក្សុរុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ កៅ កុសល្យ

កញ្ញា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដារី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ីស និងលោកម្តាយ ឌិន សៅខុន

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

## មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ " បណ្ណាគារត្រៃរតន៍ "

# 136E$_0$ វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ 012 706 581

097 905 00 55

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។